ISSN 1560-7615 / ISBN 978-99950-52-06-5


# ទស្សនាវដ្ដីអភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី ១៧ លេខ ៣ | ខែកញ្ញា ឆ្នាំ២០១៣ | តម្លៃ ១.៥០០៛


# តើអេកូទេសចរណ៍អាចលើកកម្ពស់ជីវភាពនៅមូលដ្ឋានឬទេ? ករណីសិក្សាពីសហគមន៍អេកូទេសចរណ៍ នៅភាគនិរតីប្រទេសកម្ពុជា[១]

## សេចក្ដីផ្ដើម

សហគមន៍អេកូទេសចរណ៍ (CBET) បានក្លាយជា ឧបករណ៍មានប្រជាប្រិយភាពខ្លាំងដើម្បីជំរុញ កំណើនសេដ្ឋកិច្ចសម្រាប់គ្រប់គ្នា និងបង្កើតប្រភពចំណូលថ្មីៗ ហើយក៏អាចជួយការពារទ្រព្យសម្បត្តិធម្មជាតិដូចជា ព្រៃឈើ និងជីវៈចម្រុះ ជាពិសេសនៅតាមប្រទេសកំពុងអភិវឌ្ឍន៍ (Hernandez *et al.* 2005; Honey 2008; Khanal and Babar 2007; Kiss 2004; Men 2006)។ អេកូទេសចរណ៍មាននិយមន័យយ៉ាងទូលាយថាជា "ការធ្វើដំណើរមានទំនួលខុសត្រូវខ្ពស់ទៅកាន់តំបន់ធម្មជាតិ ដោយជួយអភិរក្សបរិស្ថាន និងលើកកម្ពស់ សុខុមាលភាពប្រជាជនមូលដ្ឋាន" (TIES 2012)។ សម្រាប់ការការពារបរិស្ថាន, CBET គឺជាទម្រង់មួយនៃការគ្រប់គ្រងធនធានធម្មជាតិ ផ្អែកលើសហគមន៍ (CBNRM) ហើយក៏ដូចជាទម្រង់ផ្សេងទៀតនៃ CBNRM ដែរ CBET ស្វែងរកដំណោះស្រាយឈ្នះ-ឈ្នះ ពោលគឺ កម្លាំងគួបផ្សំជាវិជ្ជមាននៃការអភិរក្សធនធានធម្មជាតិ និងការលើកកម្ពស់កម្រិតជីវភាពនៅមូលដ្ឋាន (TIES 2012)។



គំរូសហគមន៍អេកូទេសចរណ៍ មានជោគជ័យបំផុត
នៅឃុំចំបក់ ក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ, ខែកក្កដា ឆ្នាំ២០១២

អេកូទេសចរណ៍នៅកម្ពុជា បានរីកចម្រើនយ៉ាងឆាប់រហ័សក្នុង ១០ឆ្នាំកន្លងទៅ។ តំបន់មានការទាក់ទាញពិសេស និងមានសម្រស់ធម្មជាតិល្អប្រណីត ដូចជា ព្រៃឈើ ទឹកធ្លាក់ ស្ទឹងអូរ និងសត្វព្រៃ ដែលល្បីឈ្មោះក្លាយជាគោលដៅទេសចរណ៍ដ៏មានប្រជាប្រិយភាព បានធ្វើឲ្យតំបន់អេកូទេសចរណ៍កើនចំនួនរហូតដល់ ៥៦កន្លែង (Phnom Penh Post 2013)។ តាមបណ្ដាខេត្តនៅភាគឦសាននៃប្រទេសកម្ពុជា ដែលមានសក្ដានុពលធំធេងសម្រាប់ការពង្រីក និងជំរុញអេកូទេសចរណ៍នោះ ចំនួនអ្នកទេសចរបែបធម្មជាតិ (ឬអេកូទេសចរ) ឡើងដល់ ៥៣.៣៧៤នាក់ នៅឆ្នាំ២០១២ ឬ កើន ៩,៧% បើធៀបនឹងឆ្នាំ២០០១។ អេកូទេសចរភាគច្រើនមកពីប្រទេសបារាំង ចិន អង់គ្លេស អាល្លឺម៉ង់ វៀតណាម អូស្ត្រាលី ហូឡង់ សហរដ្ឋអាមេរិក ស្វីស និងកូរ៉េខាងត្បូង។ ដោយមានសម្បត្តិធម្មជាតិដូចជា ផ្សោតប្រភេទ Irrawaddy, ទន្លេមេគង្គ, ព្រៃឈើ និងទេសភាពព្រៃភ្នំ, តំបន់ឦសានអាចទាក់ទាញភ្ញៀវទេសចរអន្តរជាតិបានរហូតដល់ ១លាននាក់ និងភ្ញៀវជាតិ ៥លាននាក់នៅឆ្នាំ២០២០ (Phnom Penh Post 2013)។

មានអត្ថបទជាច្រើនបានលើកបង្ហាញពីលទ្ធផលល្អ និងសក្ដានុពលនៃ CBET ប៉ុន្តែព័ត៌មានដែលអាចរកបានភាគច្រើន

## មាតិកា


តើអេកូទេសចរណ៍អាចលើកកម្ពស់ជីវភាពនៅមូលដ្ឋានឬទេ? ករណីសិក្សាពីសហគមន៍អេកូទេសចរណ៍ នៅភាគនិរតីប្រទេសកម្ពុជា ........ ១
ការជំរុញឲ្យការដាំស្រូវតាមកិច្ចសន្យាមានដំណើរការល្អ សម្រាប់កសិករតូចតាច និងកសិអាជីវកម្ម ........ ៨
តាមដានសេដ្ឋកិច្ច – ស្ថានភាពក្រៅប្រទេស ........ ១២
– ស្ថានភាពក្នុងប្រទេស ........ ១៥
ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI ........ ១៩
ការគោរពលើកសរសើរដល់បណ្ឌិត Pem ........ ២៤


---

[១] អត្ថបទនេះរៀបរៀងដោយ លន់ ពេជ្រតារា អ្នកស្រាវជ្រាវក្នុងកម្មវិធីបរិស្ថាន និងធនធានធម្មជាតិ។ អត្ថបទនេះផ្អែកលើលទ្ធផលបានពីការសិក្សាជាក់ស្តែងអនុវត្តដោយ Lonn *et al.* (2012)។

គឺជាការកត់សំគាល់របស់បុគ្គល ដោយពុំមានទិន្នន័យបែបបរិមាណ និងការវិភាគផ្តែកលើភស្តុតាងគ្រប់គ្រាន់នោះទេ (Kiss 2004:232)។ ការត្រួតពិនិត្យជាលក្ខណៈប្រព័ន្ធនាពេលថ្មីៗលើសហគមន៍ព្រៃឈើ ដែលជាទម្រង់មួយនៃ CBNRM ក៏បង្ហាញនូវ កង្វះខាតទិន្នន័យបែបបរិមាណ ជាពិសេសអំពីសុខុមាលភាពប្រជាជននៅមូលដ្ឋាន (Bowler *et al.* 2011)។ សរុបមក មានការសិក្សាតិចតួចណាស់ដែលបានប្រើរបៀបវាយតម្លៃលើផលប៉ះពាល់ និងប្រើវិធីសាស្ត្របែបបរិមាណ និងបែបគុណភាពដ៏សមស្រប ហើយផ្តល់ការវាស់វែងគួរឲ្យជឿជាក់អំពីប្រសិទ្ធភាពនៃ CBET (Persha *et al.* 2011)។ ដើម្បីជួយបំពេញកង្វះខាតចំណេះដឹងដូចលើកខាងលើ អត្ថបទនេះមានបង្ហាញពីលទ្ធផលសំខាន់ៗ បានពីការស្រាវជ្រាវផ្តែកលើបទពិសោធន៍ជាក់ស្តែង អនុវត្តឡើងនៅឃុំចំបក់ ខេត្តកំពង់ស្ពឺ ដើម្បីកំណត់ពីប្រសិទ្ធភាពនៃ CBET ក្នុងការអភិរក្សព្រៃឈើ និងលើកកម្ពស់ជីវភាពក្នុងមូលដ្ឋាន (Lonn *et al.* 2012)។

## ឧទ្ទេសបំណង

ករណីសិក្សានេះមានគោលដៅជារួម វាយតម្លៃពីផលប៉ះពាល់នៃ CBET ទៅលើជីវភាពនៅមូលដ្ឋានក្នុងឃុំចំបក់។ ករណីសិក្សានេះព្យាយាមឆ្លើយនឹងសំណួរស្រាវជ្រាវដ៏សំខាន់ថា តើ CBET បានជួយលើកកម្ពស់ជីវភាពនៅមូលដ្ឋានដែរឬទេ? ពិសេសទៅទៀត ការសិក្សានេះសំដៅប្រៀបធៀបប្រភពចំណូលចម្បងៗ រវាងគ្រួសារជាសមាជិក CBET និង គ្រួសារមិនមែនសមាជិក CBET នៅចន្លោះឆ្នាំ ២០០២ និង ២០១០ នៅមុនពេល និងក្រោយពេលបង្កើត CBET ។

## វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ប្រើប្រាស់កម្រងសំណួរដែលបានរៀបចំឡើងយ៉ាងម៉ត់ចត់ ដើម្បីប្រមូលព័ត៌មានស្តីពី ការផ្លាស់ប្តូរក្នុងស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចរបស់គ្រួសារ ពីឆ្នាំ២០០២ ដល់ ២០១០។ ក្របខ័ណ្ឌសំណាក រួមមាន ១៧៤ គ្រួសារ ឬប្រហែល ២៣% នៃប្រជាជនសរុបក្នុងឃុំ ហើយក្នុងនោះមាន ៧៧គ្រួសារជាសមាជិក CBET និង ៩៧គ្រួសារមិនមែនជាសមាជិក CBET ដែលគេបានជ្រើសរើសដើម្បីធ្វើសម្ភាសន៍នៅខែសីហា ២០១១។

កម្រងសំណួរសម្រាប់បំពេញ ត្រូវបានពិនិត្យផ្ទៀងផ្ទាត់ដើម្បីធានាថា ព័ត៌មានបានពីអង្កេត មានលក្ខណៈស៊ីគ្នាល្អ ពេញលេញ និងត្រឹមត្រូវ រួមទាំងការលើកឡើងពីហេតុផលនៃការផ្លាស់ប្តូរក្នុងកម្រិតជីវភាព និងពេលវេលាដែលការផ្លាស់ប្តូរទាំងនោះបានកើតឡើង។ ព័ត៌មានបានពីអង្កេតគ្រួសារ គេយកមកចងក្រង និងប្រើប្រាស់ ដើម្បីវាយតម្លៃពីភាពខុសគ្នានៅក្នុងប្រាក់ចំណូល និងលក្ខណៈសំគាល់ផ្សេងទៀត រវាងគ្រួសារជាសមាជិក CBET នឹងគ្រួសារមិនមែនសមាជិក CBET។ ព័ត៌មានទទួលបានពីការពិភាក្សាតាមក្រុមស្នូល និងសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ បានយកមកផ្ទៀងផ្ទាត់ និងបំពេញបន្ថែមលើទិន្នន័យអង្កេតគ្រួសារ។

ដើម្បីវាយតម្លៃពីការផ្លាស់ប្តូរក្នុងជីវភាពរស់នៅ ការសិក្សានេះបានបែងចែកគ្រួសារជាបីក្រុមគឺ៖ "ក្រុមប្រសើរឡើងបន្តិច", "ក្រុមគ្មានផ្លាស់ប្តូរ" និង "ក្រុមខ្សត់ខ្សោយ"។ គ្រួសារក្នុងក្រុមទី១ រាយការណ៍ពីការប្រសើរឡើងខ្លះក្នុងកម្រិតជីវភាព ដូចជាប្រាក់ចំណូលកើនឡើង (>១ដុល្លារ/ថ្ងៃ/នាក់) ផ្ទះសម្បែងប្រសើរឡើង ចំណាយលើអាហារកើនឡើង និងសន្តិសុខស្បៀងប្រសើរឡើង ជាដើម។ គ្រួសារក្នុង "ក្រុមគ្មានផ្លាស់ប្តូរ" បានជួបការលំបាក ឬឧបសគ្គមួយចំនួនតូចៗ។ គ្រួសារក្នុង "ក្រុមខ្សត់ខ្សោយ" មានជីវភាពរស់នៅយ៉ាប់យ៉ឺន ដូចជា ប្រាក់ចំណូលទាប (<១ដុល្លារ/ថ្ងៃ/នាក់) គ្មានគោក្របី គ្មានទ្រព្យសម្បត្តិ និងផ្ទះសម្បែងយ៉ាប់យ៉ឺន ហើយអ្នកខ្លះត្រូវពឹងពាក់លើជំនួយពីមូលនិធិអភិវឌ្ឍន៍សហគមន៍ ដើម្បីដោះទ័ល។

ដើម្បីវាស់វែងពីសក្តានុពលនៃអេកូទេសចរណ៍ ក្នុងការបង្កើតចំណូលមានសមធម៌ និងចីរភាព សម្រាប់សហគមន៍មូលដ្ឋាននោះ ការសិក្សានេះបានគណនា មេគុណ Gini ដែលជារង្វាស់វិសមភាពចំណូលស្តង់ដារមួយ ដោយកំណត់តម្លៃចាប់ពី 0 (សមភាពពេញលេញ) ដល់ ១ (វិសមភាពពេញលេញ) ទៅលើប្រាក់ចំណូលដែលគ្រួសារបានពីកសិកម្ម សកម្មភាពមិនមែនកសិកម្ម ព្រៃឈើ និងអេកូទេសចរណ៍។

## តំបន់សិក្សា

ឃុំចំបក់ ស្ថិតក្នុងស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ត្រូវបានជ្រើសរើសសម្រាប់ករណីសិក្សានេះ ដោយសារ (១) ជាគំរូ CBET មានជោគជ័យបំផុត, (២) ស្ថិតនៅជិតតំបន់ការពារធម្មជាតិ (ឧទ្យានជាតិគិរីរម្យ) និង (៣) មានទម្រង់ផ្សេងៗនៃ CBNRM និង CBET កំពុងដំណើរការ។ កន្លែងទាក់ទាញភ្ញៀវទេសចរខ្លាំងជាងគេគឺ ទឹកធ្លាក់ដ៏គួរឲ្យគយគន់កម្ពស់ជាង ៤០ម៉ែត្រ ស្ថិតនៅក្នុងព្រៃចាស់យូរមកហើយមួយកន្លែង។ សកម្មភាពទេសចរណ៍ពេញនិយមដទៃទៀត រួមមាន ការធ្វើដំណើរក្នុងព្រៃ ការជិះកង់កម្សាន្ត ការលបមើលសត្វស្លាប និងការទស្សនាល្ពាងសត្វប្រចៀវ។

ឃុំចំបក់ ចែកជា ៤ភូមិ មានប្រជាជនសរុប ៣៦៧០នាក់ ឬ ៧៦១គ្រួសារដែលមានសមាជិកជាមធ្យម ៤,៦នាក់ នៅក្នុងឆ្នាំ២០១០[២]។ ឃុំមានផ្ទៃដីសរុប ៨២៥៧ហិកតា ហើយប្រហែលពាក់កណ្តាលស្ថិតក្នុងឧទ្យានជាតិគិរីរម្យ (រូបភាព ១)។ ក្នុងឃុំមាន CBNRM ៣ប្រភេទ កំពុងដំណើរការ គឺ៖ ១) សហគមន៍ព្រៃឈើ (CF) បង្កើតឡើងដោយរដ្ឋបាលព្រៃឈើក្នុងឆ្នាំ២០០៥ ដែលមានផ្ទៃដី ២៨៦ហិកតា នៅជាប់ព្រំដែនឧទ្យានជាតិគិរីរម្យ ២) សហគមន៍តំបន់ការពារធម្មជាតិ (CPA) កំណត់ឡើងដោយក្រសួងបរិស្ថាន ក្នុងឆ្នាំ២០០២ លើផ្ទៃដី ៧៥៨ហិកតា ស្ថិតក្នុងឧទ្យានជាតិគិរីរម្យ និង ៣) តំបន់ CBET កំណត់ឡើងដោយក្រសួងបរិស្ថាន នៅឆ្នាំ២០០៣ មានផ្ទៃដី ១៦១ហិកតា ស្ថិតក្នុងឧទ្យានជាតិគិរីរម្យ (FAO 2012)។ នៅពេលកំពុងធ្វើការសិក្សានេះ មានការបោះបង្គោល និងសញ្ញាមួយចំនួនតូចសម្រាប់សំគាល់ CF និង CPAs ប៉ុន្តែតំបន់ CBET នៅខ្វះសញ្ញាកំណត់ព្រំដែនច្បាស់លាស់ ដោយសារព្រំប្រទល់ដែលបានស្នើឡើងនោះ កំពុងរង់ចាំសេចក្តីសម្រេចជាផ្លូវការពីក្រសួងបរិស្ថាន។

[២] សម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ ក្នុងខែសីហា ២០១១

រូបភាព ១៖ ឃុំចំបក់ និងតំបន់ត្រួតគ្នាជាមួយឧទ្យានជាតិគិរីរម្យ និងទីតាំងតំបន់ CBNRM និង CBET







សំគាល់៖ ៩ ភូមិដែលបានដៅនៅលើផែនទីឃុំ ត្រូវបានរួមបញ្ចូលគ្នាបង្កើតជា ៤ ភូមិ គឺ៖ ចំបក់ដង្គុំ, បេង, ក្រាំងចេក និង ថ្មី។
ប្រភព៖ អង្កេតដល់កន្លែង ខែសីហា ២០១១, តំបន់ CF - រដ្ឋបាលព្រៃឈើ (២០១០), តំបន់CPA - ម្លប់បៃតង (២០១១)

ការបង្កើត CBET គឺសម្រាប់គ្រប់គ្រងសកម្មភាពអេកូទេសចរណ៍នៅក្នុងឃុំ ដើម្បីផ្តល់នូវប្រភពចំណូលមួយទៀតដល់បណ្តាសហគមន៍ពឹងផ្អែកលើព្រៃឈើ កសាងសមត្ថភាពគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន និងលើកកម្ពស់ចំណាប់អារម្មណ៍ក្នុងមូលដ្ឋានអំពី សារៈសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព ដើម្បីទាញយកអត្ថប្រយោជន៍បានយូរអង្វែង។ សកម្មភាពទាំងនេះទទួលការទ្រទ្រង់ជាបឋមពី ម្លប់បៃតង (អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផ្នែកបរិស្ថាន) ដែលរួមសហការជាមួយ Lutheran World Federation Cambodia (LWF) ព្រមទាំងជំនួយពីក្រសួងបរិស្ថាន, រដ្ឋបាលព្រៃឈើ និងអាជ្ញាធរមូលដ្ឋាន។ ជំនួយពីខាងក្រៅបានចប់អស់នៅឆ្នាំ២០១០ នៅពេលដែល បណ្តាសហគមន៍គ្រប់គ្រងធនធានធម្មជាតិក្នុងឃុំចំបក់ បានដំណើរការដោយឯករាជ្យ ក្រោមការដឹកនាំនៃគណៈកម្មាធិការគ្រប់គ្រង ជ្រើសតាំងឡើងតាមការបោះឆ្នោតដោយមានការណែនាំជួយយោបល់ពី ម្លប់បៃតង និងក្រសួងពាក់ព័ន្ធនានា។

គណៈកម្មាធិការសហគមន៍ទេសចរណ៍ចំបក់ ស្រដៀងគ្នានឹងគណៈកម្មាធិការ CF និង CPA ដែរ ត្រូវបានជ្រើសតាំងឡើងតាមការបោះឆ្នោតរៀងរាល់ ៥ឆ្នាំ ម្តង។ មេភូមិ មេឃុំ និងអាជ្ញាធរមូលដ្ឋាន ពុំមានសិទ្ធិ បម្រើការក្នុងគណៈកម្មាធិការសហគមន៍ទេសចរណ៍ឡើយ។ គណៈកម្មាធិការនេះ មានសមាជិកសរុប ១៥នាក់ (ប្រធាន អនុប្រធាន ហិរញ្ញិក និងតំណាងមកពីតាមភូមិនីមួយៗ) ក្នុងនោះមាន ៩នាក់ជានារី[៣]។ គណៈកម្មាធិការសហគមន៍ទេសចរណ៍ មានភារកិច្ចត្រួតពិនិត្យលើសកម្មភាពអេកូទេសចរណ៍ មើលថែទាំតំបន់អេកូទេសចរណ៍ មើលគ្រប់គ្រងលើមូលនិធិសហគមន៍ទេសចរណ៍ និងបែងចែកអត្ថប្រយោជន៍រវាង សមាជិកសហគមន៍ឲ្យមានយុត្តិធម៌។ សហគមន៍ទាំងបីនេះ មានបទបញ្ញត្តិ និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់ ហើយធ្វើការរួមគ្នាដើម្បីការពារធនធានធម្មជាតិក្នុងមូលដ្ឋាន និងដើម្បីការរីកចម្រើនរបស់ប្រជាជនមូលដ្ឋាន។ ឧទាហរណ៍ គណៈកម្មាធិការសហគមន៍ទេសចរណ៍ តែងផ្តល់ជំនួយហិរញ្ញវត្ថុ ឬសម្ភារៈ ទៅឲ្យគណៈកម្មាធិការ CF និង CPA សម្រាប់បំពេញសកម្មភាពគ្រប់គ្រងផ្សេងៗ។ មានគេលើកពីភស្តុតាងជាក់ស្តែងមួយចំនួនបង្ហាញថា បទល្មើសព្រៃឈើបានថយចុះចាប់ពីឆ្នាំ២០០៣ ដោយសារមានការយាមល្បាតជាប្រចាំនៅតំបន់ CF និង CPAs ដោយក្រុមល្បាតដែលទទួលបានប្រាក់កម្រៃផ្ទាល់ពីមូលនិធិ CBT[៤]។

## លទ្ធផលសិក្សា

អេកូទេសចរណ៍ បានពាំនាំប្រាក់កាស ចូលទៅក្នុងសេដ្ឋកិច្ចមូលដ្ឋាន តាមការបង្កើតប្រភពចំណូល និងឱកាសថ្មីៗរួមមាន៖

- ថ្លៃចូលទស្សនា - រួមចំណែក ៧០% នៃចំណូលសរុបបានពីអេកូទេសចរណ៍ (Men 2006)
- ថ្លៃចំណត - រួមចំណែកប្រហែល ១៤% នៃចំណូលសរុបពីអេកូទេសចរណ៍ (Men 2006)
- ថ្លៃជួលរទេះគោ - រួមចំណែកប្រហែល ១០% នៃចំណូលសរុបពីអេកូទេសចរណ៍ (Men 2006)
- ថ្លៃជួលកង់
- ការលក់វត្ថុអនុស្សាវរីយ៍ធ្វើពីឫស្សី ឈើ ឬ ផ្តៅ
- ការដាំបន្លែ និងសិប្បកម្មគ្រួសារ
- មគ្គុទេសក៍ទេសចរណ៍
- ការសម្តែងសិល្បៈដោយសិស្សសាលាបឋមសិក្សា
- ភោជនីយដ្ឋានមួយកន្លែងដំណើរការដោយស្ត្រីសុទ្ធ - ផ្តល់នូវការងារផ្លាស់វេនគ្នាដូចជា មេចុងភៅ អ្នករត់តុ និងជំនួយការចុងភៅ ដល់ស្ត្រី ជាង ៣០០នាក់។ ចំណូលបានដល់ម្នាក់ៗមានតិចណាស់ ព្រោះពួកគេអាចធ្វើការនៅទីនោះ

[៣] សម្ភាសន៍ជាមួយប្រធានគណៈកម្មាធិការសហគមន៍ទេសចរណ៍ចំបក់ កាលពីថ្ងៃទី២៤ តុលា ២០១៣។

[៤] សម្ភាសន៍ជាមួយមេភូមិពេជ្រអន្ទង់ (ភូមិមួយក្នុងចំណោមភូមិទាំងប្រាំបួនពីមុន) ក្នុងឃុំចំបក់ កាលពីខែសីហា ២០១១។

ក្នុងអំឡុងពេលខ្លី និងតែម្តងប៉ុណ្ណោះក្នុងមួយឆ្នាំ

- ការបង្កើត ២១ក្រុមសន្សំប្រាក់មិនផ្លូវការរបស់ស្ត្រី
- អ្នកល្បាតព្រៃ
- ការស្នាក់នៅតាមផ្ទះប្រជាជន-ជាចំណូលអេកូទេសចរណ៍ចម្បងសម្រាប់គ្រួសារនីមួយៗ។ ថ្លៃស្នាក់នៅ ៣ដុល្លារ/យប់ ត្រូវបែងចែកឲ្យ មូលនិធិ CBT (០,២៥ដុល្លារ), មគ្គុទេសក៍ក្នុងមូលដ្ឋាន (០,២៥ដុល្លារ) និងម្ចាស់ផ្ទះ (២,៥ដុល្លារ)។

ទិដ្ឋភាពសំខាន់បំផុតមួយនៃ CBET គឺសមាជិកសហគមន៍ត្រូវចូលវិភាគទាន តាមភាគរយថេរមួយនៃចំណូលផ្នែកទេសចរណ៍របស់ខ្លួន ឬក៏ចូលរួមតាមតួលេខជាក់លាក់មួយដល់មូលនិធិ CBT តាមការកំណត់របស់គណៈកម្មាធិការ CBT។ រូបភាព ២ បង្ហាញថា មូលនិធិ CBT មិនបានទទួលវិភាគទានពីគ្រប់សកម្មភាពទាក់ទងនឹងអេកូទេសចរណ៍នោះទេ ដូចជាមិនទាន់បានពី ការសម្តែងសិល្បៈ ឬភោជនីយដ្ឋានដំណើរការដោយស្ត្រី ជាដើម។ ដូច្នេះត្រូវធ្វើកំណែទម្រង់គោលនយោបាយ ដើម្បីកំណត់ឲ្យមូលនិធិអភិវឌ្ឍន៍សហគមន៍ទទួលបានចំណែកណាមួយ ពីគ្រប់ចំណូលផ្នែកទេសចរណ៍។

ប្រហែល ៩៩% នៃគ្រួសារឆ្លើយសម្ភាសន៍ មានការពេញចិត្តចំពោះ CBET និង ទេសចរ ១១.២០០នាក់ ដែលមកទស្សនានៅឆ្នាំ២០១១ ក្នុងនេះមាន ៨០% ជាទេសចរកម្ពុជា (Lonn *et al.* 2012)។ គួរកត់សំគាល់ជាសំខាន់ថា ប្រជាជននៅក្នុងឃុំមិនមែនចាប់អារម្មណ៍ទាំងអស់គ្នាចូលរួមក្នុងសកម្មភាព CBET ឬក៏អាចចូលរួមដោយស្មើភាពគ្នានោះទេ។ តួយ៉ាង ការទទួលទេសចរស្នាក់នៅតាមផ្ទះ ជាគោលការណ៍ត្រូវធ្វើឡើងដោយផ្លាស់វេនគ្នាក្នុងចំណោមគ្រួសារនៅក្នុងឃុំ ប៉ុន្តែជាក់ស្តែងមានប្រហែលតែ ១០គ្រួសារប៉ុណ្ណោះ ដែលមានផ្ទះស័ក្តិសម ពោលគឺមានអនាម័យស្អាតបាត មានសន្តិសុខ រឹងមាំ និងធំល្មមសម្រាប់ទទួលទេសចរឲ្យស្នាក់នៅប្រកបដោយផាសុខភាព។ ក្នុងឆ្នាំ២០១១ នៅក្នុងឃុំចំបក់ មានផ្ទះសម្រាប់ទទួលភ្ញៀវឲ្យស្នាក់នៅចំនួន ៣៥ផ្ទះ ដែលក្នុងនោះ ភូមិថ្មី មាន ១៣ផ្ទះ, ភូមិចំបក់ជង្គំ មាន ៧ផ្ទះ, ភូមិបេង មាន ៩ផ្ទះ និងភូមិក្រាំងចេក មាន ៦ផ្ទះ។

នៅពេលសាកសួរអំពីជីវភាពរស់នៅ ៧២% នៃគ្រួសារឆ្លើយសម្ភាសន៍ បានសម្តែងការពេញចិត្តនឹងកម្រិតជីវភាពរបស់ខ្លួន។ លទ្ធផលសិក្សាបង្ហាញថា កំណើនភាពមានការងារធ្វើសម្រាប់មនុស្សពេញវ័យ (បុរស និងនារី) ជាកត្តាចម្បងជួយលើកកម្ពស់ជីវភាពនៅមូលដ្ឋាន ហើយ CBET បានរួមចំណែកដោយផ្ទាល់ និងដោយប្រយោល ក្នុងការបង្កើតឱកាសរកចំណូលសម្រាប់ប្រជាជនមូលដ្ឋាន។ ក្រៅពីការរកចំណូលពីសកម្មភាពទាក់ទងនឹងអេកូទេសចរណ៍ (មគ្គុទេសក៍ ភោជនីយដ្ឋាន សិប្បកម្ម ការជិះរទេះគោ ទេសចរស្នាក់នៅ

រូបភាព ២៖ គោលនយោបាយចំណូល និងចំណាយ នៃគណៈកម្មាធិការ CBT




ប្រភព៖ បានពី Men (2006)

តាមផ្ទះ ថ្លៃចូលទស្សនា និង ថ្លៃចំណត) ប្រជាជនមូលដ្ឋានក៏រកបានចំណូលពី ការប្រមូលនិងលក់អនុផលព្រៃឈើ, ថ្លៃឈ្នួលពលកម្ម, និងសហគ្រាសខ្នាតតូច ឬអាជីវកម្មផ្ទាល់ខ្លួន ដូចជា ការជួសជុលម៉ូតូ និងសម្ភារៈអេឡិចត្រូនិក ការលក់គ្រឿងទេស និងការធ្វើនំ។ ការលូតលាស់វិជ្ជមានមួយទៀតគឺ ការបង្កើតក្រុមជួយខ្លួនឯងមិនផ្លូវការ ជាពិសេស ក្រុមសន្សំប្រាក់របស់នារីក្នុងភូមិ។

នៅរវាងឆ្នាំ២០០២ និង ២០១០ អេកូទេសចរណ៍នៅឃុំចំបក់បានបង្កើតចំណូលប្រចាំឆ្នាំជាមធ្យម ១០.០០០ដុល្លារ (Lonn *et al.* 2012)។ ទិន្នន័យបានពីអ្នកឆ្លើយសម្ភាសន៍ដែលរកនឹកឃើញពីប្រាក់ចំណូលកាលពីឆ្នាំមុនរបស់ពួកគាត់ បានបង្ហាញថា ក្នុងឆ្នាំ២០១១ ប្រាក់ចំណូលមធ្យម (មេដ្យាន) ប្រចាំខែ គឺ ៧៤,១ ដុល្លារសម្រាប់គ្រួសារជាសមាជិក CBET (៧៧គ្រួសារ) និង ៦៤,៣ដុល្លារសម្រាប់គ្រួសារមិនមែនសមាជិក CBET (៩៦ គ្រួសារ)។ គំលាតគ្នាប៉ុណ្ណេះមិនធំគួរឲ្យកត់សំគាល់ខាងស្ថិតិទេ (with Wilcoxon signed-ranked test (p=0.3675 at >5) (តារាង១)។ តួលេខនេះបង្ហាញថា គ្រួសារជាសមាជិក CEBT និងគ្រួសារមិនមែនសមាជិក CEBT ទទួលបានប្រាក់ចំណូលប្រហាក់ប្រហែលគ្នា។

តារាង ១៖ ចំណូលប្រចាំខែរបស់គ្រួសារ (ដុល្លារ) នៅឆ្នាំ២០១១

| | ចំនួនគ្រួសារ * | មេដ្យាន | គំលាតស្តង់ដារ | Wilcoxon test (*p*-value) |
|---|---|---|---|---|
| គ្រួសារជាសមាជិក CBET | 77 | 74.1 | 112.3 | 0.3675 |
| គ្រួសារមិនមែនសមាជិក CBET | 96 | 64.3 | 65.6 | |

* ក្នុងចំណោមគ្រួសារសំណាកទាំងអស់ មានតែ ១ គ្រួសារមិនមែនសមាជិក CBET ប៉ុណ្ណោះ ដែលមិនព្រមឆ្លើយនឹងសំណួរអំពីប្រភពចំណូលរបស់ខ្លួន។

ការប្រៀបធៀបនូវរបាយប្រភពចំណូលចម្បងៗ តាមគ្រួសារបង្ហាញថា ចំណូលអេកូទេសចរណ៍ មានកម្រិតវិសមភាពខ្ពស់ជាងប្រភពចំណូលផ្សេងទៀត ដោយមានមេគុណ Gini 0,៧៣ (តារាង២)។ គ្រួសារក្នុងក្រុមបញ្ចភាគចំណូលខ្ពស់បំផុត (បញ្ចភាគទី១) អាចក្តោបក្តាប់យកអស់ ៨០% នៃចំណូលពីអេកូទេសចរណ៍ ព្រោះពួកគេមានផ្ទះមានគុណភាពល្អសមរម្យ សម្រាប់ឲ្យទេសចរស្នាក់នៅ និងមានទ្រព្យសកម្មផ្សេងទៀត ដូចជា រទេះគោជាដើម រីឯគ្រួសារក្នុងក្រុមបញ្ចភាគចំណូលទាបបំផុត (បញ្ចភាគទី៥) មិនមាន ឬមានទ្រព្យសកម្មតិចតួច និងទទួលបានតែ ១% នៃចំណូលពីអេកូទេសចរណ៍ប៉ុណ្ណោះ។ អេកូទេសចរណ៍រួមចំណែកតិចបំផុត (៧,៧% ឬ ១០,៥ដុល្លារ) ក្នុងចំណូលប្រចាំខែជាមធ្យមរបស់គ្រួសារជាសមាជិក CBET (រូបភាព ៣)។

រូបភាព ៣៖ ចំណូលប្រចាំខែជាមធ្យម បែងចែកតាមប្រភពចំណូល (ដុល្លារ) ក្នុងឆ្នាំ២០១១




តារាង ២៖ បំណែងចែកប្រាក់ចំណូលគ្រួសារ នៅឃុំចំបក់ពីខែសីហា ២០១០ ដល់ សីហា ២០១១ (ភាគរយ)

| ប្រភពចំណូល | បញ្ចភាគទី១ (lowest 20%) | បញ្ចភាគទី៥ (highest 20%) | មេគុណ Gini |
|---|---|---|---|
| កសិកម្ម (n = ១៦៣គ្រួសារ) | 4.4 | 49.0 | 0.4 |
| អេកូទេសចរណ៍ (n = ៦៨គ្រួសារ) | 1.0 | 80.6 | 0.7 |
| ព្រៃឈើ (n = ៩១គ្រួសារ) | 1.5 | 62.9 | 0.6 |
| មិនមែនកសិកម្ម (n = ១៣០គ្រួសារ) | 1.7 | 54.2 | 0.5 |
| សរុប (n = ១៧៣គ្រួសារ) | 4.0 | 48.7 | 0.4 |

អ្នកឆ្លើយសម្ភាសន៍ភាគច្រើនប្រាប់ថា ស្ថានភាពរស់នៅរបស់ខ្លួនក្នុងឆ្នាំ២០១១ បាន "ប្រសើរឡើងបន្តិច" បើធៀបនឹងឆ្នាំ ២០០២។ ជាទូទៅ គេមានឱកាសការងារច្រើនជាងមុន (រូបភាព ៣) ក្នុងនេះអេកូទេសចរណ៍មិនមែនជាប្រភពចំណូលចម្បងរបស់ពួកគេទេ តែជាប្រភពចំណូលបន្ថែមមួយ។ ចំណុចនេះបង្ហាញថា ការងារជាសមាសធាតុដ៏សំខាន់ក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ ឬក្នុងការលើកកម្ពស់កម្រិតជីវភាព ហើយ ភាគច្រើនរាយការណ៍ថា ខ្លួនបានបង្កើតអាជីវកម្មតូចៗ ដូចជា ជួសជុលម៉ូតូ ធ្វើនំ/នំបញ្ចុក/គុយទាវ ឬលក់គ្រឿងទេស។ អ្នកខ្លះទៀតទៅធ្វើការឲ្យក្រុមហ៊ុនចំការម៉ៅសាក់ក្នុងតំបន់នោះ។ ចំណូលជាសាច់ប្រាក់បានពីការប្រមូល និងលក់ឫស្សី ផ្តៅ និងជ្រើត គឺសម្រាប់ជួយដោះស្រាយការចាយវាយប្រចាំថ្ងៃ។ ជនវ័យក្មេងមួយចំនួនបានទៅធ្វើការជាកម្មកររោងចក្រកាត់ដេរ ឬកម្មករសំណង់នៅទីក្រុង។ អ្នកផ្តល់ព័ត៌មានគន្លឹះម្នាក់ប្រាប់ថា បើសិនគ្មានប្រភពចំណូល និងការងារទាំងនេះទេ (ក្នុងមូលដ្ឋាន និងនៅខាងក្រៅ) កិច្ចប្រឹងប្រែងបញ្ឈប់ការប្រមូលផលលើសកម្រិតពីធនធានព្រៃឈើ នៅឃុំចំបក់នឹងមិនអាចសម្រេចទៅបានឡើយ[៥]។

ទាក់ទងនឹងលទ្ធភាពទទួលបានការងារធ្វើ គ្រួសារក្នុងក្រុម "ប្រសើរឡើងបន្តិច" អាចពឹងផ្អែកលើការងារច្រើនប្រភេទ និងមានឱកាសច្រើនជាង ក្នុងការទាញយកអត្ថប្រយោជន៍ពីអេកូទេសចរណ៍ ព្រោះមានផ្ទះធំអាចទទួលឲ្យទេសចរមកស្នាក់នៅបានច្រើននាក់ជាង គ្រួសារមានផ្ទះតូចៗក្នុងក្រុម "ខ្សត់ខ្សោយ"។ សន្តិសុខ ជាកត្តាមួយទៀតដែលជះឥទ្ធិពលដល់ជោគជ័យក្នុង

[៥] សម្ភាសន៍ជាមួយសមាជិកសហគមន៍មួយរូប នៅខែសីហា ២០១១។

ការផ្ដល់កន្លែងស្នាក់នៅឲ្យទេសចរ។ គ្រួសារមានជីវភាពធូរធារភាគច្រើន មានផ្ទះស្ថិតកណ្ដាលឃុំ ក្បែរមជ្ឈមណ្ឌល CBET ដែលមានសន្តិសុខល្អជាងសម្រាប់ឲ្យទេសចរស្នាក់នៅ បើធៀបទៅនឹងភូមិនៅឆ្ងាយៗ។ ទោះបីមានគោលការណ៍កំណត់ឲ្យគ្រួសារនានាផ្លាស់វេនគ្នាទទួលទេសចរឲ្យស្នាក់នៅ ដើម្បីបែងចែកប្រាក់ចំណូលពីការស្នាក់នៅនោះឲ្យបានស្មើភាពគ្នាក្ដី ក៏ផលចំណេញនោះបានជារឿយៗជាងទៅដល់ គ្រួសារមានជីវភាពធូរធារ។

រូបភាព ៤៖ មូលហេតុនៃការផ្លាស់ប្ដូរជីវភាព ចាប់ពីឆ្នាំ២០០២




ប្រភព៖ សម្ភាសន៍តាមគ្រួសារ នៅឃុំចំបក់ ខេត្តកំពង់ស្ពឺ ក្នុងខែសីហា ២០១១

នៅពេលសាកសួរពីការផ្លាស់ប្ដូរជីវភាពរស់នៅ ទាំងគ្រួសារជាសមាជិក និងមិនមែនសមាជិក CBET នៅក្នុងក្រុម "ជីវភាពខ្សត់ខ្សោយ" និង "ជីវភាពគ្មានផ្លាស់ប្ដូរ" ប្រាប់ថា កម្រិតជីវភាពរបស់ពួកគាត់បានធ្លាក់ចុះ ដោយសារកង្វះការងារមានប្រាក់កម្រៃ និងការខូចខាតផលស្រូវក្នុងពេលមានគ្រោះរាំងស្ងួតឆ្នាំ២០១១ (រូបភាព ៤)។ ប្រភពធនធានធម្មជាតិក៏ចោទបញ្ហាដែរ។ សំពាធចំនួនប្រជាជន និងកំណើនតម្រូវការធនធានធម្មជាតិដែលកំពុងតែកេរចរិលទៅ បានកាត់បន្ថយបរិមាណអនុផលព្រៃឈើដែលគ្រួសារនានាអាចប្រមូលយកបាន ធ្វើឲ្យពួកគាត់រកចំណូលបានទាបជាងមុន និងមានជម្រើសតិចជាងមុនក្នុងការរកចិញ្ចឹមជីវិត។ ក្រៅពីភាពកម្រនៃធនធាននោះ កង្វះកម្លាំងពលកម្មក្នុងគ្រួសារ និងការលំបាកក្នុងការដឹកជញ្ជូនអនុផលព្រៃឈើ ដូចជា ឫស្សី និងផ្ដៅ ធ្វើឲ្យគ្រួសារមិនមែនសមាជិក CBET ភាគច្រើន អាចប្រមូលអនុផលព្រៃឈើបានត្រឹមតែមួយរស់ប៉ុណ្ណោះ។ ម្យ៉ាងទៀត គ្រួសារនៅក្នុងក្រុមទាំងពីរនេះក៏បានរាយការណ៍ពី ការឈឺថ្កាត់ និងមរណភាពនៃសមាជិកគ្រួសារផងដែរ។ ការថែទាំសមាជិកគ្រួសារមានជម្ងឺ ទាមទារនូវការចំណាយប្រាក់ និងកម្លាំងពលកម្មក្នុងគ្រួសារ ហើយការបាត់បង់សមាជិកគ្រួសារ វាដាក់សម្ពាធជាខ្លាំងទៅលើគ្រួសារដែលកំពុងខ្វះខាតនូវធនធានសម្រាប់ធ្វើផលិតកម្ម ក្នុងនោះមានទាំងកម្លាំងពលកម្មផង ក្នុងការរកចំណូលឲ្យបានគ្រប់គ្រាន់។

## ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

ភាពមានការងារធ្វើជាកត្តាចម្បងមួយ ក្នុងការប្រែប្រួលប្រសើរឡើងនៃជីវភាពក្នុងតំបន់។ ទោះជា CBET នៅចំបក់ បានទាក់ទាញភ្ញៀវទេសចរទស្សនាជាច្រើននាក់ ជួយបង្កើតការងារដោយផ្ទាល់ និងដោយប្រយោល ក៏ដូចជាអត្ថប្រយោជន៍ផ្សេងៗសម្រាប់ប្រជាជនក្នុងមូលដ្ឋានក្ដី ក៏ចំណូលបន្ថែមបានពីទេសចរណ៍នៅមានតិចតួច ហើយឱកាសថ្មីៗ អាចផ្ដល់ត្រឹមតែប្រាក់ចំណូលបន្ថែមខ្លះៗប៉ុណ្ណោះ។ ការសិក្សាមិនបានរកឃើញចំណងទាក់ទងផ្នែកស្ថិតិគួរឲ្យកត់សំគាល់ទេ រវាង CBET នឹងប្រាក់ចំណូលប្រសើរឡើងរបស់គ្រួសារ។ ភាពខុសគ្នារវាង ចំណូលប្រចាំខែមធ្យម (មេដ្យាន) របស់គ្រួសារជាសមាជិក CBET និងគ្រួសារមិនមែនសមាជិក CBET អាចបកស្រាយបានតាមភាពខុសពីគ្នានៃ វត្តមានអនុផលព្រៃឈើនៅតាមភូមិនីមួយៗ វត្តមាននិងលទ្ធភាពទទួលបានការងារ និងវិសមភាពក្នុងការបែងចែកចំណូលពីអេកូទេសចរណ៍ ធៀបទៅនឹង ប្រភពចំណូលផ្សេងទៀត។ ទោះយ៉ាងនេះក្ដី គិតជាមធ្យម អេកូទេសចរណ៍រួមចំណែក ៧,៧% ក្នុងចំណូលប្រចាំខែរបស់គ្រួសារជាសមាជិក CBET។ លទ្ធផលសិក្សាបញ្ជាក់គាំទ្រដល់ ការស្រាវជ្រាវឃើញពីមុនថា ភាពទាក់ទាញផ្នែកអេកូទេសចរណ៍ និងសេវាកម្ម អាចផ្ដល់នូវប្រភពចំណូលបន្ថែមដល់ប្រជាជនក្នុងមូលដ្ឋាន (Men 2006; Reimer and Walter 2012; Walpole and Goodwin 2001; Wunder 2000)។

គ្រួសារភាគច្រើនមានអារម្មណ៍ថា ជីវភាពរបស់ខ្លួនបានប្រសើរឡើង ចាប់ពីពេលបង្កើត CBET នៅក្នុងឃុំ ហើយគ្រួសារ ៩៥% មានការពេញចិត្តនឹង CBET។ ទោះយ៉ាងនេះក្ដី លទ្ធផលសិក្សាបង្ហាញថា CBET នៅចំបក់ នៅមិនទាន់បានអភិវឌ្ឍគ្រប់គ្រាន់ទេ ហើយមានការងារត្រូវធ្វើជាច្រើនទៀត ដើម្បីជំនះលើការលំបាកនានាដែលសហគមន៍មូលដ្ឋានកំពុងជួបប្រទះ ជាពិសេសភាពកម្រនៃធនធានធម្មជាតិ បណ្ដាលមកពីការប្រមូលយកអនុផលព្រៃឈើដោយគ្មានផែនការ និងគ្មានការគិតគូរពីចីរភាពនៃធនធាន, សិទ្ធិកាន់កាប់និងប្រើប្រាស់ដីធ្លីមិនច្បាស់លាស់, តំបន់អេកូទេសចរណ៍មិនទាន់បានកំណត់ព្រំដែនច្បាស់ និងកង្វះហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍ (ផ្លូវថ្នល់, ការផ្គត់ផ្គង់អគ្គិសនី, ការដឹកជញ្ជូន, អនាម័យ)។ បញ្ហាមួយទៀតគឺ ប្រជាជនក្នុងតំបន់នៅខ្វះខាតជំនាញ និងចំណេះដឹងចាំបាច់ផ្សេងៗ ទាក់ទងនឹង ការរៀបចំអាហារ, អនាម័យ, ការទទួលស្វាគមន៍, ការផ្ដល់មគ្គុទេសក៍ជាប្រជាជនក្នុងមូលដ្ឋាន (និងជំនាញផ្នែកភាសា), ការថែរក្សាតំបន់រមណីយដ្ឋាន និង ការគ្រប់គ្រងបរិស្ថាន។

ការជំរុញ CBET ឲ្យដំណើរការទៅមុខដើម្បីកាត់បន្ថយភាពក្រីក្រ និងវិសមភាពចំណូល បានជួបនឹងឧបសគ្គធំៗមួយចំនួនដែលត្រូវធ្វើការកែសម្រួល ដើម្បីទាញយកអត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ឲ្យបានសម្រេចដូចការរំពឹងទុក។ ទន្ទឹមគ្នានេះ CBET ក៏បង្ហាញច្បាស់ពីសក្ដានុពលក្នុងការផ្ដល់នូវប្រាក់ចំណូលបន្ថែមដោយផ្ទាល់ និងដោយប្រយោលដល់គ្រួសារនានាក្នុងមូលដ្ឋាន តាមរយៈការបង្កើតឱកាសរកចំណូល និងការងារក្នុងតំបន់នោះ។ អត្ថប្រយោជន៍មួយទៀត មិនសូវលេចធ្លោតែសំខាន់ដូចគ្នាគឺ ប្រជាជនភាគច្រើន (ប្រហែល ៩៤%) ដែលទទួលផលពីអេកូទេសចរណ៍ និងប្រភពចំណូលពាក់ព័ន្ធនានា បានកាត់បន្ថយការពឹងពាក់លើធនធានព្រៃឈើ និងមានអាកប្បកិរិយា និងការយល់ឃើញកាន់តែវិជ្ជមានចំពោះកិច្ចប្រឹងប្រែងអភិរក្សព្រៃឈើ (Walpole and Goodwin 2001)។ គំនិតផ្ដួចផ្ដើមផ្សេងៗផ្នែក CBET ទៅថ្ងៃអនាគត គួរគិតគូរពីវិធីជំរុញ

ឲ្យការបែងចែកចំណូលពីអេកូទេសចរណ៍ មានលក្ខណៈកាន់តែស្មើភាព ដើម្បីឲ្យគ្រួសារក្រីក្រអាចទទួលបានអត្ថប្រយោជន៍ពីទំនួលខុសត្រូវរបស់ខ្លួន ក្នុងការមើលថែតំបន់អេកូទេសចរណ៍។ ការបង្កើតបណ្ដាញក្នុងមូលដ្ឋាន ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលជំនាញ និងវិជ្ជាជីវៈពាក់ព័ន្ធនឹងរបៀបដំណើរការសហគ្រាសអេកូទេសចរណ៍នៅកម្ពុជា ក៏ជួយផ្ដល់នូវការងារ និងឱកាសរកចំណូលផ្សេងៗ ឲ្យបានកាន់តែច្រើនឡើងដែរ។

## ឯកសារយោង


Clements, T., A. John, K. Nielsen, D. An, S. Tan and E. Milner-Gulland (2010), "Payments for Biodiversity Conservation in the Context of Weak Institutions: Comparison of Three Programs from Cambodia", *Ecological Economics,* 69(6), pp. 1283-1291

Bowler, D.E., L.M. Buyung-Ali, J.R. Healey, J.P.G. Jones, T.M. Knight and A.S. Pullin (2011),"Does Community Forest Management Provide Global Environmental Benefits and Improve Local Welfare? *Frontiers in Ecology and the Environment,* Vol. 10 (1), pp.29-36

FA, Forest Administration (2010), *Statistics on Community Forestry in Cambodia, 2010* (Phnom Penh: Ministry of Agriculture, Forestry and Fishery)

FAO (2012), "Making Forestry Work for the Poor: Assessment of the Contribution of Forestry to Poverty Alleviation in Asia and the Pacific" RAP Publication: No.:2012/06

Hernandez Cruz, Rosa E., Eduardo Bello Baltazar, Guillermo Montoya Gomez and Erin I.J. Estrada Lugo (2005), "Social Adaptation: Ecotourism in the Lacandon Forest", *Annals of Tourism Research,* 32(3), pp. 610-627

Honey, M. (2008), *Ecotourism and Sustainable Development: Who Owns Paradise?* Second Edition (Washington, DC: Island Press)

Khanal, B.R. and J.T. Babar (2007), "Community Based Ecotourism for Sustainable Tourism Development in the Mekong Region" Policy Brief 1/2007, Hanoi Resource Center

Kiss, A. (2004), "Is Community-based Ecotourism a Good Use of Biodiversity Conservation Funds?" *Trends in Ecology & Evolution,* 19(5), pp. 232-237

Lonn, P., M. Nobuya, K. Tsuyoshi and Y. Shigejiro (2012), "Effectiveness of Community-Based Ecotourism in Forest Conservation and Livelihood Improvement: A Case Study in Chambok Community-Based Ecotourism, Cambodia", master's thesis, Kyushu University, Fukuoka, Japan

Men, P. (2006), "Tourism, Poverty, and Income Distribution: Chambok Community-based Ecotourism Development, Kirirom National Park, Kompong Speu Province, Cambodia", *Journal of GMS Development Studies*, 3(1), pp.25-38

National Institute of Statistics (2008), *Statistical Year Book Year 2008* (Phnom Penh: Ministry of Planning)

Persha, L., A. Agrawal and A. Chhatre (2011), "Social and Ecological Synergy: Local Rulemaking, Forest Livelihoods, and Biodiversity Conservation", *Science,* 331(6024), pp. 1606

Phnom Penh Post (2013), "Ecotourism in Cambodia up 9.7 percent", 14 February 2013 http://www.phnompenhpost.com/business/ecotourism-cambodia-97-cent (accessed 18 August 2013)

Porter-Bolland, L., E.A. Ellis, M.R. Guariguata, I. Ruiz-Mallén, S.Negrete-Yankelevich and V. Reyes-García (2011), "Community Managed Forests and Forest Protected Areas: An Assessment of their Conservation Effectiveness across the Tropics", *Forest Ecology and Management,* doi:10.1016/j.foreco.2011.05.034

TIES, The International Ecotourism Society (2012), "How is Ecotourism Different from Nature Tourism, Sustainable Tourism, Responsible Tourism?" http://www.ecotourism.org/book/how-ecotourism-different-nature-tourism-sustainable-tourism-responsible-tourism (accessed 2 April 2012)

Walpole, M.J. and H.J. Goodwin (2001), "Local Attitudes towards Conservation and Tourism around Komodo National Park, Indonesia", *Environmental Conservation,* 28(2), pp. 160-166

Wunder, S. (2000), "Ecotourism and Economic Incentives: An Empirical Approach", *Ecological Economics,* 32(3), pp. 465-479

# ការជំរុញឲ្យការដាំស្រូវតាមកិច្ចសន្យាមានដំណើរការល្អ សម្រាប់កសិករតូចតាច និងកសិអាជីវកម្ម[1]

## សេចក្តីផ្តើម

ក្នុងសង្គមកម្ពុជា ប្រជាជន ៨០% យករបរកសិកម្មធ្វើជាប្រភពចំណូលចម្បង និងជាមធ្យោបាយចិញ្ចឹមជីវិតរបស់ខ្លួន ក្នុងនេះប្រហែល ២លានគ្រួសារមានផ្ទៃដីដាំដុះជាមធ្យម ១ហិកតា ឬតិចជាង (Mund 2011)។ នៅឆ្នាំ២០១១ កម្ពុជាផលិតស្រូវបាន ៨,៧៨លានតោន ដែលផ្តល់ជាអតិរេកស្រូវសម្រាប់ការនាំចេញ ៣,២១លានតោន (FAO/WFP 2012: 2)។ ប៉ុន្តែការរីកលូតលាស់វិស័យស្រូវអង្ករនេះ មិនបានផ្តល់អត្ថប្រយោជន៍ជាដុំកំភួនដល់កសិករតូចតាចឡើយ ហើយការមានសមត្ថភាពទាបរបស់កសិករ ក្នុងការកែច្នៃផលស្រូវ នៅតែរារាំងដល់ការកែលំអផលិតភាព និងការពង្រីកការនាំចេញ។ ដើម្បីកាត់បន្ថយឧបសគ្គចំពោះវិស័យស្រូវអង្ករ ក្រុមហ៊ុនអង្គរកសិកម្មរុងរឿង (AKR) ដែលជាក្រុមហ៊ុនកម្ពុជាបង្កើតឡើងក្នុងឆ្នាំ ១៩៩៩ ក៏បានបង្កើតគោលនយោបាយ ស្តីពីការដាំស្រូវតាមកិច្ចសន្យាឡើង (Cai *et al.* 2008)។ សព្វថ្ងៃនេះ នៅកម្ពុជាមានព័ត៌មានតិចតួចណាស់ អំពីគម្រោងការដាំស្រូវតាមកិច្ចសន្យា ជាពិសេសទាក់ទងនឹងការឲ្យកសិករតូចតាចចូលរួម ការកាត់បន្ថយភាពក្រីក្រ របៀបរៀបចំកិច្ចសន្យា អត្ថប្រយោជន៍ និងបញ្ហាប្រឈមផ្សេងៗ។

អត្ថបទនេះបង្ហាញពី លទ្ធផលនៃការសិក្សាធំទូលាយមួយ ដែលពិនិត្យអំពីទិដ្ឋភាពបីនៃការដាំស្រូវតាមកិច្ចសន្យា និងកិច្ចព្រមព្រៀងរវាងកសិករចុះកិច្ចសន្យានឹងAKR។ទិដ្ឋភាពទាំងបីនោះ គឺការឲ្យម្ចាស់ដីកសិកម្មតូចៗចូលរួម និងរបៀបរៀបចំកិច្ចសន្យា អត្ថប្រយោជន៍នៃការដាំស្រូវតាមកិច្ចសន្យាចំពោះកសិករ និងការលំបាកដែលកសិករ និងសហគ្រាសកសិអាជីវកម្មជួបប្រទះ។ សម្រាប់ករណីសិក្សា អ្នកស្រាវជ្រាវបានជ្រើសយក AKR ព្រោះជាក្រុមហ៊ុនផលិតស្រូវតាមកិច្ចសន្យាធំបំផុតនៅកម្ពុជា។ ការវិភាគផ្អែកលើទិន្នន័យបានពី ការធ្វើសម្ភាសន៍បែបគុណភាព នៅក្នុងខេត្តកំពង់ស្ពឺ កាលពីខែឧសភា ២០១២ និង មិថុនា ២០១៣។ អ្នកឆ្លើយសម្ភាសន៍រួមមាន កសិករ ១០នាក់ មេភូមិ ៤នាក់ បុគ្គលិកឃុំ ១នាក់ បុគ្គលិក AKR ១នាក់ និង បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលក្នុងតំបន់នោះចំនួន ៣នាក់។ លទ្ធផលពីការសិក្សា នឹងរួមចំណែកជួយដោះស្រាយបញ្ហាផ្សេងៗផ្នែកគោលនយោបាយ ដែលសំខាន់ជាខ្លាំងសម្រាប់ជោគជ័យនៃការដាំស្រូវតាមកិច្ចសន្យា និងជួយដល់ការរៀបចំវិធីសាស្ត្រអភិវឌ្ឍន៍មួយដែលជម្រុញឲ្យការដាំស្រូវតាមកិច្ចសន្យា អាចដំណើរការបានសម្រាប់កសិករតូចតាច។

## ការឲ្យកសិករតូចតាចចូលរួម និងរបៀបរៀបចំកិច្ចសន្យា

នៅពេលចាប់ផ្តើមប្រតិបត្តិការដាំស្រូវតាមកិច្ចសន្យា ក្រុមហ៊ុន AKR បានពិចារណាលើកត្តាជាច្រើនក្នុងការសម្រេចជ្រើសរើសកន្លែងអនុវត្តគម្រោងការចុះកិច្ចសន្យានេះ។ កត្តាដ៏សំខាន់បំផុតគឺលក្ខខណ្ឌផ្នែកក្សេត្រសាស្ត្រ។ ស្រូវផ្កាម្លិះ ត្រូវបានជ្រើសរើសព្រោះវាជាពូជស្រូវដែលសមស្របសម្រាប់តំបន់ទំនាប ដែលពឹងផ្អែកលើទឹកភ្លៀង និងមិនសូវជួបគ្រោះទឹកជំនន់។ ដោយសារស្ថានភាពក្សេត្រសាស្ត្រមិនសមស្រប មាន ឃុំ ភូមិមួយចំនួន និងកសិករខ្លះ ដែលស្ថិតក្នុងខេត្តជាមួយគ្នាដែរ ពុំមានការអនុញ្ញាតឲ្យចូលរួមក្នុងគម្រោងការដាំស្រូវតាមកិច្ចសន្យាទេ។ លក្ខណៈវិនិច្ឆ័យមួយទៀត គឺកម្រិតប្រមូលផ្តុំផលិតកម្មនៅក្នុងតំបន់។ តម្រូវការពូជស្រូវសុទ្ធកម្រិតខ្ពស់ នាំឲ្យមានការដកចេញនូវភូមិខ្លះពីគម្រោង ដោយហេតុថាកសិករចង់ចុះកិច្ចសន្យានៅក្នុងភូមិទាំងនោះ មានដីស្រែនៅរាយប៉ាយដាច់ឆ្ងាយពីគ្នា។ ពីដំបូង ទំហំស្រែមិនមែនជា លក្ខខណ្ឌសម្រាប់ការជ្រើសរើសកសិករនោះទេ ប៉ុន្តែនៅឆ្នាំ២០០០ មានតែ ៥% នៃកសិករចុះកិច្ចសន្យាជាមួយ AKR ប៉ុណ្ណោះ ដែលមានដីស្រែតូចជាង ១ហិកតា។ ក្រោយមក ក្រុមហ៊ុន AKR ក៏គិតឃើញថា ការធ្វើការជាមួយកសិករមានដីស្រែតូចៗវាលំបាកពេក ហើយក៏បានបង្កើតវិធានកំណត់ដីស្រែ ១ហិកតានេះឡើង។ ជារឿយៗស្ថានភាពជីវភាពយ៉ាប់យ៉ឺនបានបង្ខំឲ្យកសិករមានដីស្រែតូចៗ អនុវត្តបំពានលើកិច្ចសន្យា ហើយរារាំងក្រុមហ៊ុន ក្នុងការចាត់វិធានការតាមផ្លូវច្បាប់ចំពោះពួកគាត់។ គោលនយោបាយបច្ចុប្បន្ននៃការទិញស្រូវជាសមូហភាព ជួយឲ្យកសិករមានដីស្រែតូចៗ អាចលក់ស្រូវទៅឲ្យក្រុមហ៊ុន AKR បាន ប៉ុន្តែក្រុមហ៊ុនមិនបានកត់ត្រាពីចំនួនកសិករប្រភេទនេះនៅក្នុងគម្រោងការរបស់ខ្លួនទេ។ ដូច្នេះ គម្រោងការធ្វើស្រែតាមកិច្ចសន្យា មិនបានរើសអើងចំពោះកសិករក្រីក្រ ឬក្រីក្រខ្លាំងនោះឡើយ។

ក្រុមហ៊ុន AKR បានបង្កើតជាសមាគមឃុំ ដើម្បីកសាងទំនុកចិត្តជាមួយកសិករ និងធានានូវការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើការផ្គត់ផ្គង់។ សមាគមឃុំមានតួនាទីជាច្រើន ដូចជា ជួយ AKR ជ្រើសរើសកសិករចុះកិច្ចសន្យា, វាយតម្លៃការប្តេជ្ញាចិត្ត និងភាពសមស្របផ្នែកក្សេត្រសាស្ត្ររបស់កសិករ ពិនិត្យតាមដានកសិករជាប់កិច្ចសន្យានានា និងផ្តល់ដំណឹងពីដំណើរការផលិតកម្ម និងបញ្ហាប្រឈមផ្សេងៗដល់ AKR ។

កិច្ចសន្យារវាង AKR និងកសិករ មិនមានការចូលរួមពីកសិករទេនៅពេលតាក់តែងរៀបចំឡើង។ ក្រុមហ៊ុនជាអ្នកតាក់តែងកិច្ច

---

[1] រៀបរៀងដោយ នូ កែវសុទ្ធា ជាអ្នកសម្របសម្រួលកម្មវិធី និងបណ្ឌិត ហេង ម៉ូលីយ៉ាណែត ជាអ្នកស្រាវជ្រាវ នៃកម្មវិធីអភិវឌ្ឍន៍សង្គម។ អត្ថបទនេះ សង្ខេបពីលទ្ធផលសិក្សាដែលបានអនុវត្តឡើងជាផ្នែកមួយនៃ គម្រោង ACIAR (ASEM/2009/023) ស្តីពី "ការបង្កើតគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវ នៅប្រទេសឡាវ និងកម្ពុជា" ដែលគ្រោងបញ្ចប់នៅខែឧសភា ២០១៤។

សន្យា ហើយកសិករក៏ចុះហត្ថលេខាលើនោះ។ កិច្ចសន្យាមានចែងពីលក្ខខណ្ឌដ៏ចាំបាច់មួយចំនួន ប៉ុន្តែនៅខ្វះចំណុចសំខាន់ៗជាច្រើន។ ការចុះកិច្ចសន្យាផ្គត់ផ្គង់ស្រូវឲ្យ AKR ជួយឲ្យកសិករទទួលបាន គ្រាប់ពូជមានគុណភាពខ្ពស់ (ពីដំបូងមានតែស្រូវផ្កាម្លិះប៉ុណ្ណោះ ប៉ុន្តែថ្មីៗនេះទៀត មានស្រូវ ផ្ការំដួល និងអង្គង់សីយ ផងដែរ) សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ទីផ្សារមានការធានាល្អ និងថ្លៃស្រូវមានលក្ខណៈប្រកួតប្រជែង។ កិច្ចសន្យាគ្មានបញ្ជាក់ពីថ្លៃទិញស្រូវទេ ប៉ុន្តែមានចែងថា កសិករនឹងទទួលបាន ៦០រៀល/គីឡូក្រាម លើសពីថ្លៃទីផ្សារនៅពេលលក់ស្រូវ។ ក្នុងផ្ទៃដីចុះកិច្ចសន្យាមួយហិកតាៗ AKR រំពឹងថាទទួលបានការផ្គត់ផ្គង់ស្រូវពី ១,៥ ទៅ ២,៥តោន ប៉ុន្តែវិធាននេះអាចលើកលែងបានក្នុងករណីផលស្រូវរងការខូចខាត។ កិច្ចសន្យាក៏មានបញ្ជាក់ដែរពីបរិមាណគ្រាប់ពូជដែលកសិករអាចខ្ចីបាន ប៉ុន្តែគ្មានបញ្ជាក់ពីរយៈពេលនៃការខ្ចីនោះទេ។ កិច្ចសន្យាមានចែងពី កាតព្វកិច្ចរបស់ AKR ក្នុងការចេញថ្លៃដឹកជញ្ជូនស្រូវទៅកាន់ក្រុមហ៊ុន និងបង់ថ្លៃសេវាទៅឲ្យសមាជិកសមាគមឃុំ ពីលក្ខខណ្ឌដែលក្រុមហ៊ុនទទួលទិញស្រូវពីកសិករ ពីការពិន័យលើកសិករដែលអនុវត្តបំពានលើកិច្ចសន្យា ប៉ុន្តែគ្មានចែងពីការពិន័យលើក្រុមហ៊ុនទេ។ កិច្ចសន្យាក៏គ្មានចែងពី ពេលវេលាដែលកសិករត្រូវបង្វិលសងគ្រាប់ពូជមកវិញ រយៈពេលនៃកិច្ចសន្យា និងបែបបទដែលភាគីណាមួយអាចបញ្ចប់កិច្ចសន្យាបាន។

## អត្ថប្រយោជន៍នៃការដាំស្រូវតាមកិច្ចសន្យា

លទ្ធភាពចូលទៅកាន់ទីផ្សារ ដែលមានលក្ខណៈប្រកួតប្រជែង គឺជាហេតុផលចម្បង និងសំខាន់បំផុតសម្រាប់កសិករចូលរួមក្នុងគម្រោងការដាំស្រូវតាមកិច្ចសន្យា។ ថ្លៃដែល AKR ទទួលទិញស្រូវពីកសិករ មានលក្ខណៈប្រកួតប្រជែងពីរបែប៖ ១) ថ្លៃប្រមូលទិញវាខ្ពស់ជាងច្រើន បើធៀបនឹងថ្លៃដែលកសិករអាចទទួលបានពីប្រភេទស្រូវធម្មតា ដូចជា ចុងបន្លា និង ក្រចកចាប និង ២) ថ្លៃប្រមូលទិញរបស់ AKR គឺខ្ពស់ជាងថ្លៃប្រមូលទិញរបស់ឈ្មួញក្រៅផ្លូវការ។ ប៉ុន្តែថ្លៃខ្ពស់របស់ AKR នេះ ក៏មានលក្ខខណ្ឌបង្កជាបញ្ហាប្រឈមផ្នែកផលិតកម្មច្រើនដែរ (ឧទាហរណ៍ ការតម្រូវតឹងរ៉ឹងនូវប្រភេទពូជស្រូវ និងកម្រិតសំណើម) ដែលរារាំងកសិករមួយចំនួន ក្នុងការចូលរួមចុះកិច្ចសន្យា។ វត្តមានរបស់ AKR និង មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (CEDAC) បង្កើតជាទីផ្សារមានលក្ខណៈប្រកួតប្រជែងមួយ ដែលរារាំងឈ្មួញក្រៅផ្លូវការក្នុងការបន្ទាបថ្លៃស្រូវមិនសមហេតុផល។ ដោយបានយល់ដឹងពីកម្លាំងឌីណាមិកទាំងនេះ កសិករខ្លះបានពិចារណារក្សាសមាជិកភាពរបស់ខ្លួននៅក្នុង AKR ឬ CEDAC ដើម្បីរក្សាថ្លៃទីផ្សារនៃស្រូវផ្កាម្លិះឲ្យនៅខ្ពស់រហូត ទោះបីមានបញ្ហាប្រឈមផ្នែកផលិតកម្មក្ដី។

អត្ថប្រយោជន៍សំខាន់បំផុតទី២ គឺលទ្ធភាពទទួលបានគ្រាប់ពូជគុណភាពល្អ។ នៅដំណាក់កាលដំបូងនៃការដាំស្រូវតាមកិច្ចសន្យា ដែលសម្រាប់បម្រើទីផ្សារក្នុងស្រុក និងការហូបចុកតាមផ្ទះនោះ កសិករមិនសូវយកចិត្តទុកដាក់ថា ផលស្រូវមានពូជសុទ្ធល្អប៉ុណ្ណោះនោះទេ។ នៅពេលកើតមានទីផ្សារនាំចេញ ការទទួលបានគ្រាប់ពូជគុណភាពល្អ បានក្លាយជាហេតុផលចម្បងទាក់ទាញកសិករឲ្យចូលរួមក្នុង គម្រោងការដាំស្រូវតាមកិច្ចសន្យារបស់ AKR ព្រោះ AKR មានផ្គត់ផ្គង់គ្រាប់ពូជផ្ដល់ទិន្នផលខ្ពស់ និងមានភាពសុទ្ធល្អ ដែលជាលក្ខខណ្ឌមួយសម្រាប់ទីផ្សារនាំចេញអង្ករគុណភាពខ្ពស់។ CEDAC ក៏បានទិញស្រូវផ្កាម្លិះពីកសិករដែរ ប៉ុន្តែពុំមានគោលនយោបាយផ្ដល់គ្រាប់ពូជគុណភាពល្អ ឲ្យកសិករខ្ចីឡើយ។

លទ្ធភាពទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ជាអត្ថប្រយោជន៍ទី៣ នៃការដាំស្រូវតាមកិច្ចសន្យាជាមួយ AKR។ សេវានេះមិនមែនមានតែ AKR ជាអ្នកផ្ដល់ឲ្យនោះទេ ព្រោះអង្គការមិនមែនរដ្ឋាភិបាល នៅតាមមូលដ្ឋានខ្លះ ក៏មានផ្ដល់ឲ្យកសិករដែរ។ អត្ថប្រយោជន៍បន្ទាប់បន្សំទទួលបានពី AKR មានជាអាទិ៍ ឥណទានមានការប្រាក់ទាប ការបង់ថ្លៃសេវាទៅឲ្យសមាគមឃុំ ការចេញថ្លៃដឹកស្រូវទៅក្រុមហ៊ុន និងប្រព័ន្ធវាស់វែង និងថ្លឹងត្រឹមត្រូវល្អ និងយុត្តិធម៌។

អត្ថប្រយោជន៍ដូចខាងលើ ជួយធ្វើឲ្យកសិករអាចបង្កើនប្រាក់ចំណូលពីការដាំស្រូវ។ ចំណូល និងប្រាក់ចំណេញរបស់កសិករចុះកិច្ចសន្យា មានកម្រិតខ្ពស់ជាងកសិករមិនចុះកិច្ចសន្យា (មិនធ្លាប់ចូលរួមក្នុងគម្រោង) ប៉ុន្តែនៅទាបជាងកសិករធ្លាប់បានចុះកិច្ចសន្យាកាលពីមុន (បានចូលរួមក្នុងគម្រោង និងឈប់ពីគម្រោងវិញ) (តារាង ១ និង ២)។ ភាពខុសគ្នារវាងចំណូល និងប្រាក់ចំណេញរបស់កសិករចុះកិច្ចសន្យា និងមិនចុះកិច្ចសន្យា អាចពន្យល់បានថា ជាលទ្ធផលនៃចំណេះដឹងផ្នែកផលិតកម្ម និងថ្លៃទិញស្រូវខ្ពស់ជាងដែលផ្ដល់ដោយ AKR។ ដោយឡែក កសិករធ្លាប់ចុះកិច្ចសន្យាកាលពីមុនគាត់មានលទ្ធភាពគ្រប់គ្រងបានច្រើនជាងទៅលើ ការងារផលិតកម្មដែលជាប់ទាក់ទងនឹង ការប្រើជីពូជសុទ្ធ និងកម្រិតសំណើម ព្រោះគាត់លក់ស្រូវទៅឲ្យឈ្មួញក្រៅផ្លូវការដែលមិនដាក់លក្ខខណ្ឌអ្វីលើការទិញឡើយ។

## បញ្ហាប្រឈមនៃការដាំស្រូវតាមកិច្ចសន្យា

ភាពសុទ្ធនៃគ្រាប់ពូជ និងកម្រិតសំណើមទាប ជាលក្ខណៈវិនិច្ឆ័យសំខាន់បំផុតពីរ ដែលគេប្រើដើម្បីកំណត់ថា ស្រូវមានគុណភាពល្អសមស្រប សម្រាប់នាំចេញទៅទីផ្សារអង្ករគុណភាពខ្ពស់។ អតីតកសិករធ្លាប់ចុះកិច្ចសន្យាជាមួយ AKR មួយចំនួន បានលើកឡើងថា ការមិនអាចបំពេញតាមលក្ខណៈវិនិច្ឆ័យសំខាន់ទាំងពីរចំណុចខាងលើនេះ (ភាពសុទ្ធនៃគ្រាប់ពូជ និងកម្រិតសំណើមទាប) គឺជាមូលហេតុចម្បង ដែលគាត់បញ្ឈប់កិច្ចសន្យាជាមួយ AKR ទោះបីជាក្រុមហ៊ុនឲ្យថ្លៃខ្ពស់ជាងក្ដី។ ឈ្មួញក្រៅផ្លូវការឲ្យថ្លៃទាបជាងក៏ពិតមែន ប៉ុន្តែមិនមានដាក់លក្ខខណ្ឌអ្វីឡើយ។ AKR យល់ឃើញថា បរាជ័យក្នុងការផលិតស្រូវ មានពូជសុទ្ធកម្រិតខ្ពស់របស់កសិករ គឺបណ្ដាលមកពីកង្វះការប្ដេជ្ញាចិត្ត។ នេះជាមូលហេតុដែលក្រុមហ៊ុន បានលុបចោលកិច្ចសន្យាជាមួយពួកគេ។ ប៉ុន្តែក្រុមហ៊ុន ក៏ដឹងពីកង្វះខាតរបស់ខ្លួនដែរ ដែលមិនមានម៉ាស៊ីនសម្ងួតស្រូវ សម្រាប់ឲ្យក្រុមហ៊ុនអាចទិញស្រូវសើមពីកសិករតែម្ដង។ កង្វះខាតនេះ ធ្វើឲ្យ AKR មិនអាចបំពេញបានតាមតម្រូវការនាំចេញ ជាពិសេសតម្រូវការពីទីផ្សារអង្ករគុណភាព

ខ្ពស់ ហើយក្រុមហ៊ុនត្រូវបង្ខំចិត្ត ទិញស្រូវស្ងួតជាស្រេចពីឈ្មួញក្រៅផ្លូវការ។

លទ្ធភាពតិចក្នុងការទទួលបានគ្រាប់ពូជគុណភាពខ្ពស់ ជាបញ្ហាប្រឈមមួយទៀតចំពោះកសិករ។ លក្ខខណ្ឌនៃកិច្ចសន្យាតម្រូវឲ្យ AKR ផ្ដល់គ្រាប់ពូជឲ្យកសិករខ្ចីដោយមិនគិតការប្រាក់ ប៉ុន្តែកិច្ចសន្យាគ្មានបញ្ជាក់ពីខួបនៃការផ្ដល់កម្ចីទេ។ គ្រោះរាំងស្ងួត និងកង្វះការប្ដេជ្ញាចិត្តរបស់កសិករចុះកិច្ចសន្យា បានធ្វើឲ្យថយចុះទិន្នផលស្រូវ និងកម្រិតសុទ្ធល្អនៃពូជស្រូវ ដែលជាការខាតបង់យ៉ាងធ្ងន់សម្រាប់ AKR។ ដោយរៀនសូត្រពីបទពិសោធន៍នេះ ក្រុមហ៊ុនផ្ដល់កម្ចីគ្រាប់ពូជ ដល់ឃុំមួយចំនួនតូច ដែលក្រុមហ៊ុនយល់ឃើញថា កសិករមានការប្ដេជ្ញាចិត្តអនុវត្តតាមការតម្រូវដ៏តឹងរ៉ឹងរបស់ខ្លួន។ អង្គការក្នុងមូលដ្ឋាន ក៏មានផ្ដល់គ្រាប់ពូជឲ្យកសិករខ្ចីដែរ ប៉ុន្តែគម្រោងនោះមិនអាចផ្គត់ផ្គង់កសិករបានគ្រប់គ្នាទេ ហើយគ្រាប់ពូជផ្ដល់ឲ្យ ក៏ខុសគ្នាពីប្រភេទស្រូវដែល AKR ទទួលទិញផងដែរ។

ការបង់ប្រាក់មិនទៀងទាត់របស់ AKR សម្រាប់ទូទាត់ថ្លៃដឹកស្រូវទៅដល់ក្រុមហ៊ុន និងថ្លៃសេវារបស់សមាគមឃុំ បានបង្កការលំបាកដល់កសិករចុះកិច្ចសន្យា និងសមាជិកសមាគម។ កិច្ចសន្យាចែងថា AKR ត្រូវបង់ថ្លៃចំណាយទាំងនេះ ប៉ុន្តែក្នុងការអនុវត្តជាក់ស្ដែង ក្រុមហ៊ុនមិនបានបំពេញកាតព្វកិច្ចនេះទៀងទាត់ទេ។ ប្រការនេះបង្កឲ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុដល់កសិករចុះកិច្ចសន្យា។ ក្រុមហ៊ុនក៏បានសន្យាទៀតថា នឹងផ្ដល់ប្រាក់ ៣០រៀល ទៅឲ្យមេឃុំ និង ៤០រៀល ទៅឲ្យមេភូមិ សម្រាប់រាល់ការផ្គត់ផ្គង់អង្ករ ១គីឡូក្រាម ដោយសមាជិករបស់ពួកគាត់ ប៉ុន្តែ ក្រុមហ៊ុនអនុវត្តតាមការសន្យានេះតែម្ដងម្កាលប៉ុណ្ណោះ។ កិច្ចសន្យាបានកំណត់តាមផ្លូវច្បាប់នូវកាតព្វកិច្ចរបស់គូភាគី ប៉ុន្តែ កសិករមិនមានសិទ្ធិអំណាចតម្រូវឲ្យក្រុមហ៊ុនទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន ឬទាមទារសំណងលើការបំពានកិច្ចសន្យានោះឡើយ។ ខាង AKR វិញ ក៏ត្រូវប្រឈមមុខនឹងការអនុវត្តខុសកិច្ចសន្យា ដែលបង្កឡើងដោយកសិករដែរ។ AKR ក៏

តារាង ១៖ ទិន្នផល ថ្លៃ និងប្រាក់ចំណូល ទទួលបានលើស្រូវវស្សា គិតតាមប្រភេទកសិករ (ឆ្នាំ ២០១២)

| | ឯកតា | អតីតកសិករ ចុះកិច្ចសន្យា | អតីតកសិករ ចុះកិច្ចសន្យា | កសិករមិនចុះ កិច្ចសន្យា |
|---|---|---|---|---|
| ទំហំដី | ហិកតា | 1 | 1 | 1 |
| ទិន្នផល | គីឡូក្រាម/ហិកតា | 2500 | 2000 | 2000 |
| ថ្លៃ | រៀល/គីឡូក្រាម | 1350 | 1450 | 1350 |
| ចំណូលសរុប | រៀល/ហិកតា | 3375000 | 2900000 | 2700000 |
| ចំណូល៖ កសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | | 200000 | 0 |
| | % | | 107 | 100 |
| ចំណូល៖ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករចុះកិច្ចសន្យា | រៀល/ហិកតា | 475000 | 0 | |
| | % | 116 | 100 | |
| ចំណូល៖ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | 675000 | | 0 |
| | % | 125 | | 100 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើព័ត៌មានបានពីសម្ភាសន៍

តារាង ២៖ ការប្រៀបធៀបប្រាក់ចំណេញ គិតតាមប្រភេទកសិករ (ឆ្នាំ២០១២)

| | ឯកតា | អតីតកសិករ ចុះកិច្ចសន្យា | កសិករចុះកិច្ចសន្យា | កសិករមិនចុះ កិច្ចសន្យា |
|---|---|---|---|---|
| ចំណូលសរុប | រៀល/ហិកតា | 3375000 | 2900000 | 2700000 |
| ចំណាយសរុប | រៀល/ហិកតា | 1230000 | 986000 | 1000000 |
| ប្រាក់ចំណេញ | រៀល/ហិកតា | 2145000 | 1914000 | 1700000 |
| ប្រាក់ចំណេញ៖ កសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | | 214000 | 0 |
| | % | | 113 | 100 |
| ប្រាក់ចំណេញ៖ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករចុះកិច្ចសន្យា | រៀល/ហិកតា | 231000 | 0 | |
| | % | 112 | 100 | |
| ប្រាក់ចំណេញ៖ អតីតកសិករចុះកិច្ចសន្យា ធៀបនឹងកសិករមិនចុះកិច្ចសន្យា | រៀល/ហិកតា | 445000 | | |
| | % | 126 | | 100 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើព័ត៌មានបានពីសម្ភាសន៍

បានលើកឡើងនូវបញ្ហាចម្បងស្តីពី ការលក់ទៅទីផ្សារខាងក្រៅខុសពីកិច្ចសន្យា ពោលគឺ កសិករបានលក់ទៅឲ្យឈ្មួញផ្សេងទៀតនូវស្រូវដែលត្រូវលក់ទៅឲ្យ AKR។ ទោះជាយ៉ាងនេះក្តី ក៏មកទល់សព្វថ្ងៃ មិនទាន់មានសមាជិកចុះកិច្ចសន្យាណាមួយដែលត្រូវជាប់ពិន័យ ដោយសារការអនុវត្តបំពានកិច្ចសន្យានោះទេ។ បញ្ហាមួយទៀតដែល AKR លើកឡើង គឺការប្រើប្រាស់មិនត្រឹមត្រូវនូវប័ណ្ណសមាជិក។ តាមសេចក្តីរាយការណ៍ កសិករខ្លះបានឲ្យសាច់ញាតិ ឬមិត្តភក្តិខ្លួនខ្ចីប័ណ្ណនោះប្រើប្រាស់ ឬ "ជួល" ទៅឲ្យឈ្មួញក្រៅផ្លូវការ ដែលយកប័ណ្ណនោះទៅប្រើ ដើម្បីបានចំណេញពីថ្លៃទិញស្រូវខ្ពស់របស់ AKR។

ការទទួលបានឥណទានមិនគ្រប់គ្រាន់ បានបង្កឧបសគ្គជាច្រើនដល់កសិករចុះកិច្ចសន្យា និង AKR ។ កសិករដែលខ្វះខាតឥណទាន ត្រូវបង្ខំចិត្តលក់ស្រូវទៅឲ្យឈ្មួញក្រៅផ្លូវការ បន្ទាប់ពីការប្រមូលផល ដើម្បីទទួលបានប្រាក់ភ្លាមៗ។ ស្រដៀងគ្នានេះដែរ កសិករក៏ស្ទាក់ស្ទើរក្នុងការផ្គត់ផ្គង់ស្រូវទៅឲ្យ AKR ដោយសារក្រុមហ៊ុនច្រើនតែពន្យាពេល ការទូទាត់ប្រាក់ទៅឲ្យកសិករ ដែលជាហេតុនាំឲ្យពួកគេជួបការលំបាកផ្នែកហិរញ្ញវត្ថុ។ បន្ថែមលើនេះទៀត កសិករចុះកិច្ចសន្យា ដែលមានកាតព្វកិច្ចផ្គត់ផ្គង់ស្រូវទៅឲ្យ AKR ត្រូវបានក្រុមហ៊ុនជំពាក់ ដែលបណ្តាលឲ្យកសិករមួយចំនួនធំ ត្រូវចាកចេញពីគម្រោងការដាំស្រូវតាមកិច្ចសន្យា។ ផ្ទុយទៅវិញ ឈ្មួញក្រៅផ្លូវការតែងសម្រួលដល់ការលក់ដូររបស់កសិករ ដោយមិនដាក់លក្ខខណ្ឌទាក់ទងនឹងកម្រិតសំណើម និងពូជសុទ្ធ និងដោយបង់ប្រាក់ឲ្យភ្លាមៗ។ ចាប់ពីឆ្នាំ ២០១០ មក ក្រុមហ៊ុនបានកែលំអរបៀបរបបហិរញ្ញវត្ថុរបស់ខ្លួន ហើយបង់ប្រាក់ទៅឲ្យសមាជិកខ្លួនភ្លាម នៅពេលដឹកស្រូវដល់ក្រុមហ៊ុន ប៉ុន្តែ គេនៅមិនទាន់ច្បាស់លាស់ទេថា AKR អាចបង់ប្រាក់ភ្លាមៗដូច្នេះបានយូរប៉ុណ្ណា។ ឧបសគ្គផ្នែកឥណទាន ក៏រារាំង AKR ក្នុងការធ្វើវិនិយោគលើឧបករណ៍សម្ងួតស្រូវ ដែលអាចជួយក្រុមហ៊ុនឲ្យបន្ធូរលក្ខខណ្ឌតឹងតែង ស្តីពីកម្រិតសំណើម និងទទួលទិញស្រូវសើមពីកសិករបាន។

គ្រោះធម្មជាតិ មានផលប៉ះពាល់អវិជ្ជមានដោយផ្ទាល់ ទៅលើផលិតកម្មស្រូវរបស់កសិករចុះកិច្ចសន្យា និងមានផលប៉ះពាល់ដោយប្រយោលទៅលើ AKR។ ការខូចខាតផលស្រូវដោយសារគ្រោះរាំងស្ងួត បានប៉ះទង្គិចធ្ងន់ធ្ងរណាស់ទៅលើកសិករ ពោលគឺទិន្នផលអាចចុះទាបធ្វើឲ្យពួកគេមិនអាចផលិតស្រូវបានគ្រប់គ្រាន់ដើម្បីបំពេញតាមកិច្ចសន្យា។បុគ្គលិកAKRបានរាយការណ៍ថាការខាតបង់ជារឿយៗដោយសារគ្រោះរាំងស្ងួត បានបង្ខំឲ្យក្រុមហ៊ុនត្រូវបញ្ឈប់កិច្ចសន្យាជាមួយឃុំជាច្រើន ដែលងាយរងគ្រោះដោយបាតុភូតធម្មជាតិនេះ។

## សេចក្តីសន្និដ្ឋាន និងជម្រើសគោលនយោបាយ

សរុបមក របៀបចុះកិច្ចសន្យាធ្វើកសិកម្មរបស់ AKR បានវិវត្តទៅមុខ ដោយផ្តល់លទ្ធភាពកាន់តែច្រើនឡើងទៅឲ្យគ្រួសារក្រីក្រ និងគ្រួសារក្រីក្របំផុតចូលរួម ជាពិសេស តាំងពីការដាក់អនុវត្ត គោលនយោបាយទិញជាសមូហភាព។ ការទទួលបានអត្ថប្រយោជន៍សំខាន់ៗ បានបង្កើនប្រាក់ចំណេញ ដែលកសិករចុះកិច្ចសន្យាទទួលបានពីដំណាំស្រូវ។ ប៉ុន្តែការអនុវត្តកិច្ចសន្យាមិនបានល្អ និងការតម្រូវឲ្យផលិតផលស្រូវមានគុណភាពខ្ពស់ បានបង្កើតបញ្ហាប្រឈមច្រើនស្មុគស្មាញ ដែលត្រូវតែដោះស្រាយ បើសិនចង់ឲ្យការធ្វើកសិកម្មតាមកិច្ចសន្យា ផ្តល់ផលប្រយោជន៍ដល់ទាំងកសិករតូចតាច និងសហគ្រាសកសិពាណិជ្ជកម្ម។ កិច្ចសន្យាធ្វើកសិកម្មផ្តោតចំទិសល្អ អាចជួយបង្កើនអត្ថប្រយោជន៍ដល់ភាគីទាំងពីរ និងចូលរួមចំណែកដល់ការអភិវឌ្ឍវិស័យស្រូវអង្ករ និងកាត់បន្ថយភាពក្រីក្រនៅជនបទ។ ខាងក្រោមនេះ ជាជម្រើសគោលនយោបាយមួយចំនួន ដែលរដ្ឋាភិបាលគួរពិនិត្យពិចារណា៖

១. **បង្កើនចំណាប់អារម្មណ៍របស់កសិករ អំពីបន្ទុកចំណាយ និងអត្ថប្រយោជន៍នៃការធ្វើកសិកម្មតាមកិច្ចសន្យា៖** ការមានជំនាញកាន់តែប្រសើរអំពីការធ្វើអាជីវកម្ម អាចជួយឲ្យកសិករមានការតាំងចិត្តខ្ពស់ បំពេញតាមកិច្ចសន្យាជាមួយ AKR។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) អាចផ្តល់ព័ត៌មាន និង/ឬ ការបណ្តុះបណ្តាលអំពី ការវិភាគចំណាយ និងផលចំណេញ តាមរយៈសេវាផ្សព្វផ្សាយបច្ចេកទេសរបស់ខ្លួន ឬក៏តាមសមាគមក្នុងឃុំនានា ដែល AKR បានបង្កើតឡើង។

២. **លុបបំបាត់ឧបសគ្គបច្ចេកទេស លើការសម្ងួតស្រូវ៖** MAFF អាចរួមសហការជាមួយ វិទ្យាស្ថានអន្តរជាតិស្រាវជ្រាវដំណាំស្រូវ (IRRI) ដើម្បីផ្តល់ការបណ្តុះបណ្តាលពីបច្ចេកទេសសម្ងួត ហើយរដ្ឋាភិបាលអាចលើកទឹកចិត្តវិស័យឯកជន (ឧទាហរណ៍ រោងចក្រកិនស្រូវ) ឲ្យធ្វើវិនិយោគលើបច្ចេកទេសសម្ងួត និង/ឬ ផ្តល់កម្ចី/ឥណទានកសិកម្ម ឲ្យ AKR ធ្វើវិនិយោគលើម៉ាស៊ីនសម្ងួតស្រូវខ្នាតធំ។

៣. **បង្កើនលទ្ធភាពដល់កសិករ ក្នុងការទទួលបានពូជស្រូវមានគុណភាពខ្ពស់ និងការស្រោចស្រព៖** ពូជស្រូវផ្សេងៗដែលអាជ្ញាធរមូលដ្ឋានកំពុងចែកចាយសព្វថ្ងៃ ដូចជា សែនពិដោរ និងផ្កាម្លិះ គឺសមស្របជាងសម្រាប់ការហូបចុកក្នុងគ្រួសារ។ រដ្ឋាភិបាលគួរសម្របសម្រួលការងារជាមួយ អ្នកនាំចេញអង្ករ ដើម្បីផ្តល់អាទិភាពដល់ពូជស្រូវដែលត្រូវជម្រុញឡើង និងចែកចាយពូជស្រូវមានគុណភាពខ្ពស់ក្នុងគោលដៅផលិតស្រូវអង្ករ ដែលស្របតាមតម្រូវការទីផ្សារនាំចេញ។ គោលនយោបាយសម្រាប់កែលំអហេដ្ឋារចនាសម្ព័ន្ធស្រោចស្រព និងដែនគ្រប់ដណ្តប់ មានចុះនៅក្នុងគោលនយោបាយស្រូវ។ ដូច្នេះ រដ្ឋាភិបាល អាចជួយឲ្យកសិករកាន់តែមានលទ្ធភាពទទួលបានពូជស្រូវល្អ និងការស្រោចស្រព តាមការពន្លឿនការអនុវត្តគោលនយោបាយស្រូវបច្ចុប្បន្ន (RGC 2010)។

៤. **បន្ធូរការរឹតត្បិតឥណទានដល់កសិករ និងសហគ្រាសកសិពាណិជ្ជកម្ម៖** ការកែលំអលទ្ធភាពរបស់កសិករក្នុងការទទួលបានឥណទាន អាចជួយកាត់បន្ថយបញ្ហាលក់ស្រូវក្រៅកិច្ចសន្យា។ ការលើកកម្ពស់លទ្ធភាពសហគ្រាសកសិពាណិជ្ជកម្មក្នុងការទទួលបានឥណទានកសិកម្ម និង/ឬ ការបង្កើនឧបត្ថម្ភធន អាចជួយឲ្យមានវិនិយោគកាន់តែច្រើនទៅលើរោងចក្រកិនស្រូវ និងម៉ាស៊ីនសម្ងួត ហើយបន្ធូរបន្ថយតម្រូវការ

សាច់ប្រាក់ សម្រាប់ធ្វើការទូទាត់ជាទៀងទាត់ឲ្យកសិករ ហើយវិធីនេះ ក៏ជួយកែលំអលំហូរសាច់ប្រាក់របស់កសិករផងដែរ។ ចំណុចនេះអាចសម្រេចបាន តាមការពន្លឿន ការអនុវត្តគោលនយោបាយស្រូវបច្ចុប្បន្ននេះដែរ (RGC 2010)។

៥. **បង្កើតអង្គភាពថ្នាក់ក្រោមជាតិមួយ សម្រាប់ការពង្រឹងអនុវត្ត និងធ្វើច្បាប់គ្រប់គ្រងកិច្ចសន្យា៖** វិធីនេះអាចជួយឲ្យកសិករ និងសហគ្រាសកសិពាណិជ្ជកម្ម មានអំណាច តថ្លៃស្មើគ្នា និងជួយកាត់បន្ថយករណីបំពានលើកិច្ចសន្យាពីសំណាក់ភាគីណាមួយ។ ដើម្បីអាចដំណើរការដោយមានប្រសិទ្ធភាពល្អ អង្គភាពនេះគួរអនុញ្ញាតឲ្យកសិករមកទាក់ទងខ្លួនបាន និងគួរមានសមាសភាពមកពីទាំងបួនក្រុម គឺកសិករ អាជ្ញាធរមូលដ្ឋាន សហគ្រាសកសិពាណិជ្ជកម្ម និង MAFF (ដែលជាក្រសួងជាប់ពាក់ព័ន្ធ)។

## ឯកសារយោង


Cai, J., L.Ung, S.Setboonsarng and P. Leung (2008), "Rice Contract Farming in Cambodia: Empowering Farmers to Move beyond the Contract toward Independence", ADBI Discussion Paper 109 (Tokyo: Asian Development Bank Institute)

Mund, Jan-Peter (2011), "The Agriculture Sector in Cambodia: Trends, Processes and Disparities", *Pacific News,* No. 35, pp. 10-14

RGC, Royal Government of Cambodia (2010), *Policy Paper on the Promotion of Paddy Production and Rice Export* (Phnom Penh: Council of Ministers)

FAO/WFP, Food and Agriculture Organisation and World Food Programme (2012), *FAO/WFP Crop and Food Security Update Mission to Cambodia* (Rome: FAO and WFP)


# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[1]

ផ្នែកនេះរៀបរាប់ពី សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅក្នុងពិភពលោក នៅអាស៊ីខាងត្បូង និងអាស៊ីខាងកើត។

សេដ្ឋកិច្ចពិភពលោកហាក់កំពុងរើបឡើងវិញ ប៉ុន្តែភាពមិនប្រាកដប្រជា និងភាពងាយរងគ្រោះនៅតែកើតមានជាបន្ត ដោយសារសេដ្ឋកិច្ចប្រទេសឧស្សាហកម្មធំៗ នៅមានកំណើនយឺត និងបន្តឡើងចុះ។ តំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីខាងកើត នៅតែជាកម្លាំងជំរុញចម្បងនៃការរើបសេដ្ឋកិច្ចពិភពលោក ថ្វីបើប្រទេសខ្លះមានកំណើនយឺតជាងមុនក្តី។

នៅត្រីមាសទី១ កំណើន ផសស ពិតនៅឥណ្ឌូនេស៊ីធ្លាក់ចុះបន្តិចមកត្រឹម ៥,៨% ធៀបនឹង ៦,០% កាលពីត្រីមាសមុន និង ៦,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស របស់ម៉ាឡេស៊ី កើនដល់ ៤,៣% ធៀបនឹង ៤,១% កាលពីត្រីមាសមុន ប៉ុន្តែធ្លាក់ចុះបើធៀបនឹងអត្រា ៥,៤% កាលពីមួយឆ្នាំមុន។ កំណើន ផសស នៅសិង្ហបុរី កើនខ្ពស់បំផុតគិតចាប់ពីឆ្នាំ២០១១ មក ដល់ ៣,៧% ធៀបនឹង ១,៩% កាលពីមួយឆ្នាំមុន។ សេដ្ឋកិច្ចប្រទេសចិន រីកលូតលាស់យឺតជាងមុនបន្តិច ប៉ុន្តែនៅតែមានកំណើនដ៏លឿនបំផុតមួយ ដោយមានអត្រាជាមធ្យម ៧,៦% សម្រាប់រយៈពេល ៥ត្រីមាសចុងក្រោយ។ ផសស ពិតរបស់ចិន នៅត្រីមាសទី២ ធ្លាក់ចុះបន្តិចមកត្រឹម ៧,៥% ធៀបនឹង ៧,៧% កាលពីត្រីមាសមុន និង ៧,៦% កាលពីឆ្នាំមុន។ មានការវាយស្មានថា សេដ្ឋកិច្ចចិនអាចកើនយឺតជាងមុន ប្រសិនបើចិនមិនធ្វើការកែតម្រូវរចនាសម្ព័ន្ធដ៏ចាំបាច់ៗនោះទេ។ បញ្ហាជាច្រើន ដូចជា អំពើពុករលួយរបស់មន្ត្រីជាន់ខ្ពស់, អប្រសិទ្ធភាពនៃសហគ្រាសរដ្ឋ និងបរិយាកាសអាជីវកម្មមានការរើសអើង ចំពោះវិនិយោគិនបរទេស គឺត្រូវតែដោះស្រាយ។ ប្រទេសចិនក៏ត្រូវស្វែងរកដំណោះស្រាយដោយសន្តិវិធីលើ បញ្ហាជម្លោះដណ្តើមដែនកោះមួយចំនួន ដើម្បីកុំឲ្យវាឈានដល់ការប្រើសកម្មភាពយោធា ហើយខូចខាតដល់សេដ្ឋកិច្ច និងនយោបាយ។ កំណើន ផសស ពិតនៅហុងកុង កើនដល់ ៣,៣% ធៀបនឹង ២,៨% កាលពីត្រីមាសមុន ហើយកំណើន ផសស ពិតនៅកូរ៉េខាងត្បូង កើនដល់ ២,៣% ធៀបនឹង ១,៥% កាលពីត្រីមាសមុន។

នៅត្រីមាសទី២ ការរើបសេដ្ឋកិច្ចឡើងវិញនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ។ កំណើន ផសស បានរួមចុះមកដល់ ០,៧% ធៀបនឹង ១,១% កាលពីត្រីមាសទី១។ ភាពគ្មានការងារធ្វើ ជាពិសេសក្នុងចំណោមយុវជន នៅមានកម្រិតខ្ពស់នៅតាមបណ្តាប្រទេស ដូចជា អេស្ប៉ាញ និង អ៊ីតាលី ជាដើម។ ការសម្រេចបានសមត្ថភាពប្រកួតប្រជែងក្នុងចំណោមប្រទេសជាសមាជិក ក៏ជាបញ្ហាប្រឈមមួយដែរ។ សេដ្ឋកិច្ចជប៉ុន មានកំណើនយឺតត្រឹម ០,៤% ធៀបនឹង ២,៨% កាលពីមួយឆ្នាំមុន។ សហរដ្ឋអាមេរិកបន្តមានដំណើរការសេដ្ឋកិច្ចល្អ បើធៀបនឹងប្រទេសមានសេដ្ឋកិច្ចជឿនលឿនដទៃទៀត ទោះបីកំណើនធ្លាក់ចុះបន្តិចនៅត្រីមាសទី២ មកត្រឹម ១,៤% ធៀបនឹង ១,៨% កាលពីត្រីមាសមុនក្តី។

---

[1] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ប៉ុន្តែមានការវាយស្មានថា សហរដ្ឋអាមេរិក អាចរួមចុះសេដ្ឋកិច្ចម្តងទៀត ដោយសារមានការទាល់ច្រកផ្នែកនយោបាយលើបញ្ហាថវិកា និងការបង្កើនកម្រិតអតិបរមានៃបំណុល។ ការបិទសេវាកម្មរដ្ឋាភិបាលមួយចំនួន បានប៉ះពាល់ដល់អាជីវកម្មនានា ដោយកាត់បន្ថយចំណាយប្រើប្រាស់ផ្ទាល់ខ្លួន របស់មន្ត្រីដែលត្រូវគេផ្អាកពីការងារ។ បញ្ហានេះក៏អាចជះឥទ្ធិពលលើ ដំណើរការរើបឡើងវិញនៃសេដ្ឋកិច្ចពិភពលោកដែរ។

## អតិផរណាពិភពលោក និងអត្រាប្តូរប្រាក់

អតិផរណានៅត្រីមាសទី២ មានលក្ខណៈសមរម្យនៅស្ទើរតែគ្រប់ប្រទេស។ នៅកម្ពុជាអតិផរណាឡើងដល់២,២%ធៀបនឹង១,៥% កាលពីត្រីមាសមុន ប៉ុន្តែវាធ្លាក់ចុះបើធៀបនឹងអត្រា២,៩%កាលពីមួយឆ្នាំមុន។ អតិផរណានៅវៀតណាម បន្តធ្លាក់ចុះមកដល់៦,៦% ធៀបនឹង ៨,៦% កាលពីមួយឆ្នាំមុន។ នៅជប៉ុនមានការធ្លាក់ចុះថ្លៃទំនិញសរុប ដែលបង្កជាសម្ពាធរុញឲ្យអត្រាការប្រាក់កើនឡើង។ បរិត្តផរណានៅតែបន្តកើតមាននៅជប៉ុន ទោះបីមានការចាប់ផ្តើមធ្វើចំណាយដ៏ច្រើនសម្បើម ស្របតាមគោលនយោបាយ **“Abenomics”** ក្តី។

នៅត្រីមាសទី២ ទល់នឹងប្រាក់ដុល្លារ ប្រាក់រៀលធ្លាក់ថ្លៃ ០,៩% ធៀបនឹងត្រីមាសមុន ប៉ុន្តែឡើងថ្លៃ ០,៥% ធៀបនឹងមួយឆ្នាំមុន។ ប្រាក់រូពីយ៉ាឥណ្ឌូនេស៊ី ធ្លាក់ថ្លៃ ១,១% ធៀបនឹងត្រីមាសមុន (៥,៤% ធៀបនឹងមួយឆ្នាំមុន)។ ប្រាក់រីងហ្គីតម៉ាឡេស៊ី ឡើងថ្លៃ ៣,២% ធៀបនឹងត្រីមាសមុន។ ប្រាក់បាតថៃ ធ្លាក់ថ្លៃ ០,៣% ធៀបត្រីមាសមុន ប៉ុន្តែឡើងថ្លៃ ៤,៥% ធៀបមួយឆ្នាំមុន។ ប្រាក់អឺរ៉ូ នៅថេរ ប៉ុន្តែប្រាក់យេនជប៉ុន ធ្លាក់ថ្លៃ ៧,០% (២៣,៣% ធៀបមួយឆ្នាំមុន) ដែលបានជួយជំរុញថែមទៀតនូវភាពប្រកួតប្រជែងផ្នែកនាំចេញរបស់ជប៉ុន។

## ថ្លៃទំនិញលើទីផ្សារពិភពលោក

នៅត្រីមាសទី២ ពោតធ្លាក់ថ្លៃ ៤,៥% ធៀបនឹងត្រីមាសមុន មកនៅ ២៩១,៤ដុល្លារ/តោន ប៉ុន្តែឡើងថ្លៃ ៧,៧% បើធៀបមួយឆ្នាំមុន។ ប្រេងឆាធ្លាក់ថ្លៃ ០,៣% (២១,៥% ធៀបមួយឆ្នាំមុន) មកនៅ ៨៥០,៣ដុល្លារ/តោន ហើយកៅស៊ូធ្លាក់ថ្លៃ ១៧,៦% (២៥,៧% ធៀបមួយឆ្នាំមុន) មកនៅ ២៤៩៧ដុល្លារ/តោន។ នៅត្រីមាសដដែលនេះ អង្ករថៃធ្លាក់ថ្លៃ ៦,១% ធៀបត្រីមាសមុន (កើន ៥,០% ធៀបមួយឆ្នាំមុន) ដល់ ៥៧០ដុល្លារ/តោន ប៉ុន្តែសណ្តែកសៀងឡើងថ្លៃ ២,០% (៤,៣% ធៀបមួយឆ្នាំមុន) ដល់ ៥៦៩,៨ដុល្លារ/តោន។ ប្រេងឆៅធ្លាក់ថ្លៃ ៧,៩% (៥,៤% ធៀបមួយឆ្នាំមុន) មកនៅ ១០០,៩ដុល្លារ/ធុង។ នៅសហរដ្ឋអាមេរិក សាំងធ្លាក់ថ្លៃ ៤,៨% ធៀបត្រីមាសមុន (៣,៨% ធៀបមួយឆ្នាំមុន) មកនៅ ០,៧១ដុល្លារ/លីត្រ ហើយម៉ាស៊ូតធ្លាក់ថ្លៃ ៧,២% (២,៨% ធៀបមួយឆ្នាំមុន) មកនៅ ០,៧៦ដុល្លារ/លីត្រ។ ការធ្លាក់ថ្លៃជារួមនៃទំនិញចម្បងៗ ព្រមទាំងប្រេងឆៅ និងឧស្ម័ន បានបង្ហាញមួយចំណែក ពីការថយចុះចំណាយប្រើប្រាស់របស់ប្រទេសមានសេដ្ឋកិច្ចកំពុងផុសឡើង ដូចជា ចិន ជាដើម។ កិច្ចប្រឹងប្រែងរបស់សហរដ្ឋអាមេរិក ដើម្បីក្លាយជាប្រទេសឯករាជ្យផ្នែកថាមពលនោះ អាចកាត់បន្ថយតម្រូវការប្រេង ហើយដាក់សម្ពាធឲ្យថ្លៃប្រេងធ្លាក់ចុះ។

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 6.8 | 0.1 | - | - | - | - | - | - | - | - | - | - |
| ឥណ្ឌូណេស៊ី | 6.1 | 4.2 | 6.2 | 6.5 | 6.5 | 6.5 | 6.3 | 6.4 | 6.2 | 6.1 | 6.0 | 5.8 |
| ម៉ាឡេស៊ី | 4.6 | -2.4 | 9.0 | 4.0 | 5.8 | 5.2 | 4.7 | 5.4 | 5.2 | 6.4 | 4.1 | 4.3 |
| សិង្ហបុរី | 1.1 | -4.5 | 14.7 | 0.9 | 5.9 | 3.6 | 1.6 | 1.9 | 0.3 | 1.5 | 0.2 | 3.7 |
| ថៃ | 2.6 | 3.3 | 7.9 | 2.6 | 3.5 | -9.0 | 0.0 | 4.2 | 3.3 | 19.5 | 5.4 | 2.6 |
| វៀតណាម | 6.2 | 4.7 | 6.7 | 5.7 | 7.2 | 6.1 | - | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 9.0 | 8.2 | 10.4 | 9.5 | 9.1 | 8.9 | 8.1 | 7.6 | 7.4 | 7.9 | 7.7 | 7.5 |
| ហុងកុង | 2.4 | -3.2 | 6.9 | 5.1 | 4.3 | 3.0 | 4.2 | 3.6 | 1.3 | 2.5 | 2.8 | 3.3 |
| កូរ៉េខាងត្បូង | 2.2 | -1.0 | 6.1 | 3.4 | 3.4 | 3.4 | 3.0 | 2.4 | 1.5 | 1.6 | 1.5 | 2.3 |
| តៃវ៉ាន់ | 0.1 | -3.6 | 11.1 | 4.9 | 3.4 | 1.9 | 0.4 | -0.2 | 1.0 | 3.7 | 1.7 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 0.9 | -3.8 | 1.6 | 1.6 | 1.4 | 0.7 | 0.0 | -0.4 | -0.6 | -0.9 | 1.1 | -0.7 |
| ជប៉ុន | -0.7 | -5.4 | 4.1 | -1.0 | 0.0 | -1.0 | 2.8 | 3.5 | 0.1 | 0.5 | 0.4 | 0.9 |
| សហរដ្ឋអាមេរិក | 1.1 | -2.5 | 2.7 | 1.5 | 1.6 | 1.6 | 2.1 | 2.2 | 2.5 | 1.6 | 1.8 | 1.4 |

Sources: IMF, Economist and countries' statistic offices

### តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា | 19.7 | -0.5 | 4.1 | 6.2 | 6.7 | 4.9 | 5.5 | 2.9 | 1.6 | 1.8 | 1.5 | 2.2 |
| ឥណ្ឌូណេស៊ី | 10.1 | 4.7 | 5.1 | 5.9 | 4.7 | 4.1 | 3.8 | 4.5 | 4.5 | 4.4 | 5.3 | 5.7 |
| ម៉ាឡេស៊ី | 5.3 | 0.4 | 1.7 | 3.3 | 3.4 | 3.2 | 2.3 | 1.7 | 1.4 | 1.3 | 1.4 | 1.8 |
| សិង្ហបុរី | 6.5 | 0.5 | 2.9 | 4.7 | 5.5 | 5.5 | 4.9 | 5.2 | 4.2 | 4.0 | 3.6 | 1.6 |
| ថៃ | 5.5 | -0.9 | 3.1 | 4.1 | 4.1 | 4.0 | 3.4 | 2.6 | 2.9 | 3.2 | 3.1 | 2.3 |
| វៀតណាម | 23.3 | 7.3 | 9.0 | 19.4 | 22.5 | 19.8 | 16.0 | 8.6 | 5.6 | 7.0 | 6.9 | 6.6 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន | 5.9 | -0.8 | 3.2 | 5.7 | 6.3 | 4.6 | 3.8 | 2.9 | 1.9 | 2.1 | 2.4 | 2.4 |
| ហុងកុង | 4.3 | -0.3 | 2.4 | 5.1 | 6.5 | 5.7 | 5.2 | 4.2 | 3.1 | 3.8 | 2.2 | 4.0 |
| កូរ៉េខាងត្បូង | 4.6 | 2.8 | 3.0 | 4.2 | 4.8 | 4.1 | 2.9 | 2.4 | 1.6 | 1.7 | 1.4 | 1.1 |
| តៃវ៉ាន់ | 3.2 | -1.1 | 1.0 | 1.6 | 1.3 | 1.4 | 1.3 | 1.6 | 3.0 | 1.9 | 1.8 | 0.8 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ | 3.3 | 0.4 | 1.6 | 2.7 | 2.7 | 2.9 | 2.7 | 2.5 | 2.5 | 2.3 | 1.8 | 1.5 |
| ជប៉ុន | 1.4 | -1.3 | -0.7 | 0.3 | 0.2 | -0.3 | 0.3 | 0.2 | -0.4 | -0.2 | -0.3 | -0.3 |
| សហរដ្ឋអាមេរិក | 3.8 | -0.4 | 1.7 | 3.5 | 3.8 | 3.3 | 2.8 | 1.9 | 1.7 | 1.9 | 1.7 | 1.4 |

Sources: International Monetary Fund, Economist and National Institute of Statistics

### តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារអាមេរិកនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | | | |
| កម្ពុជា (រៀល) | 4054.2 | 4140.5 | 4187.1 | 4044.9 | 4095.7 | 4071.9 | 4046.0 | 4054.3 | 4060.2 | 3995.9 | 3995 | 4032.9 |
| ឥណ្ឌូណេស៊ី (រូពីយ៉ា) | 9699.0 | 10413.8 | 9089.9 | 8593 | 8625.8 | 8985.7 | 9078.6 | 9281.3 | 9490.3 | 9614.6 | 9681.9 | 9783.6 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.3 | 3.5 | 3.2 | 3.0 | 3.0 | 3.2 | 3.1 | 3.1 | 3.1 | 3.1 | 3.1 | 3.0 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.4 | 1.5 | 1.4 | 1.2 | 1.2 | 1.3 | 1.3 | 1.3 | 1.6 | 1.2 | 1.2 | 1.2 |
| ថៃ (បាត) | 33.4 | 34.3 | 31.7 | 30.3 | 30.2 | 31.0 | 31.0 | 31.3 | 31.3 | 30.7 | 29.8 | 29.9 |
| វៀតណាម (ដុង) | 16,382.0 | 17,725.2 | 19200.8 | 20,693.6 | 20,699.6 | 20,997.7 | 20,971.2 | 20,849.7 | 20,847.5 | 20,839.3 | 20,829.6 | 20,828.0 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | | | |
| ចិន (យ៉ន់) | 6.9 | 6.8 | 6.76 | 6.5 | 6.4 | 6.36 | 6.3 | 6.3 | 6.4 | 6.2 | 6.2 | 6.2 |
| ហុងកុង (ដុល្លារហុងកុង) | 7.8 | 7.8 | 7.77 | 7.8 | 7.8 | 7.78 | 7.8 | 7.8 | 7.8 | 7.8 | 7.8 | 7.8 |
| កូរ៉េខាងត្បូង (វ៉ុន) | 1137.2 | 1277.8 | 1156.3 | 1084.3 | 1084.9 | 1144.87 | 1131.2 | 1152.6 | 1132.9 | 1089.9 | 1085.9 | 1123.4 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 31.5 | 33.0 | 31.3 | 28.9 | 29.2 | 30.26 | 29.7 | 29.6 | 29.8 | 29.2 | 29.5 | 29.9 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.8 | 0.7 | 0.8 | 0.7 | 0.7 | 0.74 | 0.8 | 0.8 | 0.8 | 0.8 | 0.8 | 0.8 |
| ជប៉ុន (យ៉េន) | 102.5 | 93.6 | 87.8 | 81.7 | 77.9 | 77.78 | 79.3 | 80.1 | 78.6 | 81.3 | 92.3 | 98.8 |

Sources: International Monetary Fund, Economist and National Bank of Cambodia

### តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៨-២០១៣ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2008 | 2009 | 2010 | 2011 | | | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ពោត (US No. 2) - USA (USD/តោន) | 218.2 | 167.3 | 167.3 | 311.6 | 302.8 | 270.8 | 277.5 | 270.5 | 327.1 | 310.9 | 305.2 | 291.4 |
| ប្រេងឆា-អឺរ៉ុបពាយព្យ (USD/តោន) | 912.2 | 686.8 | 834.7 | 1147.0 | 1079.0 | 1024.7 | 1106.7 | 1083.3 | 993.0 | 809.3 | 852.7 | 850.3 |
| កៅស៊ូ SMR 5 (USD/តោន) | 2586.3 | 1884.8 | 3152.2 | 4968.8 | 4617.6 | 3658.0 | 3701.2 | 3361.0 | 2799.2 | 2941.5 | 3029.5 | 2497.2 |
| អង្ករ (Thai 100%B) - បាងកក (USD/តោន) | 615.3 | 524.5 | 456.2 | 514.3 | 581.3 | 610.3 | 549.0 | 600.3 | 595.7 | 597.0 | 607.0 | 570.0 |
| សណ្តែកសៀង (US No. 1) - USA (USD/តោន) | 460.4 | 414.0 | 375.4 | 525.7 | 514.0 | 454.8 | 490.8 | 546.5 | 649.4 | 577.8 | 558.4 | 569.8 |
| ប្រេងឆៅ - OPEC spot (USD/ធុង) | 95.4 | 60.5 | 71.6 | 113.3 | 108.9 | 109.1 | 117.3 | 106.7 | 106.6 | 107.3 | 109.5 | 100.9 |
| សាំង - US Gulf Coast (សេន/លីត្រ) | 62.2 | 42.9 | 49.8 | 78.7 | 74.6 | 68.5 | 79.0 | 74.0 | 71.6 | 73.4 | 74.8 | 71.2 |
| ម៉ាស៊ូត (ស្តាន់ដ៏តិច លេខ២) - US Gulf Coast (សេន/លីត្រ) | 76.20 | 43.05 | 51.6 | 75.7 | 77.3 | 77.3 | 83.8 | 77.8 | 81.1 | 80.3 | 81.5 | 75.6 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច-ស្ថានភាពក្នុងប្រទេស[១]

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

ក្នុងត្រីមាសទី២ ឆ្នាំ២០១៣ សេដ្ឋកិច្ចកម្ពុជា បានងើបឡើងវិញពីការធ្លាក់ចុះក្នុងត្រីមាសមុន។ ថ្វីបើនៅមានភាពមិនច្បាស់លាស់ផ្នែកនយោបាយផុសចេញពី លទ្ធផលបោះឆ្នោតថ្នាក់ជាតិនៅខែកក្កដាក្តី ក៏គេរំពឹងថា កម្ពុជានឹងនៅតែមានកំណើនរឹងមាំ។ ធនាគារអភិវឌ្ឍអាស៊ី បានរក្សាការព្យាករណ៍របស់ខ្លួនពីកំណើន ៧,២% ក្នុងឆ្នាំនេះ។ ប៉ុន្តែគេត្រូវដោះស្រាយបញ្ហាប្រឈមផ្នែករចនាសម្ព័ន្ធនៅក្នុងអនុវិស័យចម្បងៗជាច្រើន ជាពិសេសវិស័យកាត់ដេរ និងកសិកម្ម ប្រសិនបើចង់សម្រេចឲ្យបានតាមអត្រាកំណើននេះ។

វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ អនុម័តដោយក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា នៅត្រីមាសទី២ ស្ទុះឡើង ដល់ ២០៩១លានដុល្លារ ធៀបនឹង ២១៩លានដុល្លារនៅត្រីមាសមុន នឹង ២៧៣លានដុល្លារកាលពីមួយឆ្នាំមុន។ កំណើនគួរឲ្យកត់សំគាល់នេះ ទំនងបណ្តាលមកពី កំណើនវិនិយោគក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ទោះយ៉ាងនេះក្តី វិនិយោគក្នុងវិស័យកាត់ដេរបានធ្លាក់ចុះ ៣០,២% ធៀបនឹងត្រីមាសមុន (២១,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៧៦,៤លានដុល្លារ ដែលទំនងជាដោយសារកត្តាបីយ៉ាងៈ (១) ការធ្វើពិពិធកម្មសេដ្ឋកិច្ចលើកកម្ពស់អនុវិស័យផ្សេងៗទៀត (២) កំណើនភាពងាយរងគ្រោះឡើងវិញនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប និង (៣) ភាពមិនច្បាស់លាស់ផ្នែកនយោបាយ ដែលអាចប៉ះពាល់ដល់រដ្ឋាភិបាលក្នុងការទទួលបានជំនួយពីបរទេស និងលក្ខខណ្ឌអនុគ្រោះពិសេសផ្សេងៗ។ ដោយសារសេដ្ឋកិច្ចកម្ពុជា មិនទាន់ធ្វើពិពិធកម្មបានច្រើននោះ ការធ្លាក់ចុះនេះទំនងបណ្តាលជាសំខាន់មកពីកត្តាទី២ និង ទី៣។ កូដកម្មជាញឹកញាប់ធ្វើឡើងដោយសហជីព និងសហព័ន្ធសហជីពនានា ទំនងជាបានរាំងស្ទះដល់វិនិយោគថ្មីៗក្នុងអនុវិស័យដ៏សំខាន់ៗទាំងនេះ។ វិនិយោគខាងកសិកម្ម កើនឡើងគួរឲ្យកត់សំគាល់ធៀបនឹងត្រីមាសមុន ប៉ុន្តែធ្លាក់ចុះ ៣០% ធៀបនឹងមួយឆ្នាំមុន ដែលបង្កជាបញ្ហាប្រឈមមួយចំនួនដល់ការកែលំអភាពប្រកួតប្រជែង និងផលិតភាពក្នុងវិស័យកសិកម្ម ជាពិសេសដំណាំស្រូវ។ វិនិយោគយឺតៗនេះ ក៏អាចប៉ះពាល់ដល់គោលដៅនាំចេញនៅក្នុងគោលនយោបាយស្រូវរបស់រដ្ឋាភិបាលដែរ។

នៅត្រីមាសទី២ វិនិយោគខាងផ្នែកសណ្ឋាគារ និងអាជីវកម្មជាប់ទាក់ទងនឹងទេសចរណ៍ បានកើន ១០០% ធៀបនឹងត្រីមាសមុន ដល់ ១០៦លានដុល្លារ។ កម្ពុជានៅតែបន្ត ទាក់ទាញភ្ញៀវទេសចរឲ្យបានកាន់តែច្រើន ក្នុងនេះ ភ្ញៀវទេសចរបរទេសមកដល់ក្នុងត្រីមាសទី១ បានកើន ២០,៩% បើធៀបនឹងកាលពីមួយឆ្នាំមុន។

ការងើបឡើងវិញ ក្នុងវិស័យសំណង់ដែលជាសសរស្តម្ភមួយនៃកំណើន នៅមានភាពមិនច្បាស់លាស់។ ក្នុងត្រីមាសទី២ តម្លៃអនុមតិគម្រោងសាងសង់សរុបធ្លាក់ចុះ ៣៦,៥% ធៀបនឹងត្រីមាសមុន (១៥,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ២៨២លានដុល្លារ ក្នុងនេះតួលេខសម្រាប់ភូមិគ្រឹះ និងផ្ទះធ្លាក់ចុះ ៩២,៩% (៨៤,៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១០,៣លានដុល្លារ ហើយសម្រាប់ផ្ទះល្វែងធ្លាក់ចុះ ៧១,១% (៨៥% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៣៣លានដុល្លារ។

ការនាំចេញក៏បានធ្លាក់ចុះដែរ។ ការនាំចេញសរុបក្នុងត្រីមាសទី២ ធ្លាក់ចុះ ៨,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ១៦២០,១លានដុល្លារ។ ផលិតផលកាត់ដេរដែលមានដល់ ៧៧,៧% នៃតម្លៃនាំចេញសរុបបានធ្លាក់ចុះ ១៤,៦% មកត្រឹម ១២៥៩លានដុល្លារ ដែលបណ្តាលឡើងជាសំខាន់ដោយសារមានការនាំចេញតិចជាងមុនទៅសហរដ្ឋអាមេរិក(២៤,៣%) និងសហភាពអឺរ៉ុប (៥,៣%)។ ការនាំចេញផលិតផលកសិកម្ម (មានកៅស៊ូ និងអង្ករជាសំខាន់) បានកើន ៤,១% ធៀបនឹងត្រីមាសមុន (២៧,២% ធៀបនឹងមួយឆ្នាំមុន) ដល់ ១២៨,៩លានដុល្លារ ក្នុងនេះ ការនាំចេញអង្ករកើន ៥០,៦%ធៀបនឹងឆ្នាំមុន ប៉ុន្តែការនាំចេញកៅស៊ូ ឈើ និងត្រី បានធ្លាក់ចុះ។ ក្នុងត្រីមាសទី២ ការនាំចូលសរុបកើន ៤០,២% ធៀបនឹងត្រីមាសមុន (១៧,៣% ធៀបនឹងមួយឆ្នាំមុន) ដល់ ២,២ពាន់លានដុល្លារ។ ការនាំចូលប្រេងសាំងកើន ០,៦% ធៀបនឹងឆ្នាំមុន, ប្រេងម៉ាស៊ូតកើន៨,៦% និងសម្ភារៈសំណង់កើន ២៥,៩%។

## ហិរញ្ញវត្ថុសាធារណៈ

ការបន្តពង្រឹងការប្រមូលពន្ធ និងចំណូលមិនមែនពន្ធ ជាបញ្ហាសំខាន់សម្រាប់រដ្ឋាភិបាល និងសេដ្ឋកិច្ច។ នៅត្រីមាសទី២ ចំណូលសរុបកើន ២១,១% ធៀបនឹងត្រីមាសមុន (៧,៨% ធៀបនឹងមួយឆ្នាំមុន) ដល់ ២២០៥ពាន់លានរៀល ដែលទំនងបណ្តាលពីកំណើនចំណូលចរន្ត ២០,៩% ធៀបនឹងត្រីមាសមុន (១៣,៧% ធៀបនឹងមួយឆ្នាំមុន)។ ចំណូលពន្ធកើន ២៨,៥% (១៧,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ២០២៤ពាន់លានរៀល និងរួមមាន ពន្ធក្នុងស្រុក និងពន្ធលើពាណិជ្ជកម្មអន្តរជាតិ ដែលតំណាងឲ្យប្រមាណ ៩២,៣% នៃចំណូលចរន្តសរុប។ រដ្ឋាភិបាលត្រូវផ្តោតផងដែរ លើការពង្រឹងចំណូលមិនមែនពន្ធ (ឧទាហរណ៍ ចំណូលលើទ្រព្យសម្បត្តិ,ការលក់ទំនិញនិងសេវា) ដើម្បីប៉ះប៉ូវលើការថយចុះជាបន្តបន្ទាប់នៃពន្ធលើពាណិជ្ជកម្មអន្តរជាតិ(១៨,៣% នៃចំណូលពន្ធ) ដែលជាលទ្ធផលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មកម្រិតតំបន់ និងទ្វេភាគី។ ម្យ៉ាងទៀតក៏មានសញ្ញាល្អប្រសើរឡើងក្នុងកិច្ចខិតខំកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល ដោយចំណាយសរុបក្នុងត្រីមាសទី២ បានធ្លាក់ចុះ ២០,៦% ធៀបនឹងមួយឆ្នាំមុន ហើយចំណាយចរន្តធ្លាក់ចុះ ១,៤%។ចំណាយលើបៀវត្សរ៍ធ្លាក់ចុះ ១៨,៦% ប៉ុន្តែចំណាយលើឧបត្ថម្ភធន និងជំនួយសង្គមផ្សេងទៀត

[១] អត្ថបទនេះរៀបរៀងដោយលោក វ័ន្ត វឌ្ឍនា ជាអ្នកស្រាវជ្រាវ និងលោកស្រី ប៉ុន ដូរីណា ជាជំនួយការស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

កើន ២៤,៩% ដែលជាសញ្ញាបង្ហាញថា រដ្ឋាភិបាលកំពុងព្យាយាមជៀសវាងស្ថានភាពមានមន្ត្រីរាជការច្រើនពេក។ ចំណាយមូលធនធ្លាក់ចុះ ៦៦,៥% ធៀបនឹងមួយឆ្នាំមុន ដែលប៉ះពាល់ដល់ការកសាង និងថែទាំផ្លូវ ស្ពាន និងអាគាររបស់រដ្ឋ។

## អតិផរណា និងអត្រាប្តូរប្រាក់

នៅត្រីមាសទី២អតិផរណាកើនឡើងបន្តិចប៉ុន្តែស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបានត្រឹម ២,២% ធៀបនឹង ១,៥%កាលពីត្រីមាសមុន និង ២,៩%កាលពីមួយឆ្នាំមុន។ សន្ទស្សន៍ថ្លៃស្បៀងនិងភេសជ្ជៈគ្មានជាតិស្រា មានកម្រិត ២,៧% ធៀបនឹង ១,៧% កាលពីត្រីមាសមុន និង ៣,៤% កាលពីមួយឆ្នាំមុន។ ប្រាក់រៀលធ្លាក់ថ្លៃ ១,០% ធៀបនឹងត្រីមាសមុន (កើន ០,៥% ធៀបនឹងមួយឆ្នាំមុន) ទល់នឹងប្រាក់ដុល្លារអាមេរិក។ នៅត្រីមាសទី១ មាសធ្លាក់ថ្លៃ ៤,៦% ធៀបនឹងត្រីមាសមុន (៣,៤% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ១៩៧,១ដុល្លារ/ជី។ នៅត្រីមាសទី២ ម៉ាស៊ូតធ្លាក់ថ្លៃ ២,៨% ធៀបនឹងត្រីមាសមុន មកត្រឹម ៤៩៩២រៀល/លីត្រ ប៉ុន្តែឡើងថ្លៃ ១២,០% ធៀបនឹងមួយឆ្នាំមុន។ សាំងចុះថ្លៃ ២,៥% ធៀបនឹងត្រីមាសមុន (០,៦% ធៀបនឹងមួយឆ្នាំមុន) មកត្រឹម ៥២៧៤,៥ រៀល/លីត្រ។

## ការវិវត្តរូបិយវត្ថុ

នៅត្រីមាសទី១ ឆ្នាំ២០១៣ សាច់ប្រាក់ងាយស្រួលសរុបកើន ៦,៦% ធៀបនឹងត្រីមាសមុន (២២,៦% ធៀបនឹងមួយឆ្នាំមុន) ដល់ ៣០.៤៨១៣ពាន់លានរៀល ដែលបង្ហាញពីកំណើនឥណទានសម្រាប់វិនិយោគក្នុងអាជីវកម្ម។ ការផ្តល់ឥណទានដល់វិស័យឯកជនកើន ៥,៥% ធៀបនឹងត្រីមាសមុន (៣២,១% ធៀបនឹងមួយឆ្នាំមុន) ដល់ ២៤.៨២០ពាន់លានរៀល។ នៅត្រីមាសដដែល ការផ្គត់ផ្គង់រូបិយវត្ថុកើន ១១,២% (១២,៩% ធៀបនឹងមួយឆ្នាំមុន) ហើយរូបិយវត្ថុផ្សេងៗកើន ៥,៨% (២៤,៤%ធៀបនឹងមួយឆ្នាំមុន)។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ដល់កម្រិតនៃរូបិយវត្ថុក្នុងចរាចរណ៍ ដើម្បីជៀសវាងអតិផរណាជំរុញឡើងដោយរូបិយវត្ថុ ថ្វីបើតួលេខអតិផរណាមិនបានបង្ហាញពីសម្ពាធរុញឡើងបែបនេះក្តី។

## ស្ថានភាពភាពក្រីក្រ

នៅខែសីហា ចំណូលប្រចាំថ្ងៃពិត របស់ពលករពីរក្រុម ក្នុងចំណោមពលករងាយរងគ្រោះទាំង ១០ក្រុម បានធ្លាក់ចុះ បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។

អ្នកស៊ីឈ្នួលធ្វើស្រែ រកចំណូលបាន ៧៧២៣រៀល/ថ្ងៃ ឬ ៩,០% តិចជាងកាលពីមួយឆ្នាំមុន ប៉ុន្តែ ២០% ច្រើនជាងកាលពីខែឧសភា ដោយសារមានការធ្លាក់ចុះចំនួនពលករ។ ក្នុងចំណោមអ្នកឆ្លើយសម្ភាសន៍ មាន ៥៤% ធ្វើការស្ទើរពេញៗមួយខែ រីឯពលករដទៃទៀតធ្វើការតិចជាងម្ភៃថ្ងៃក្នុងមួយខែ។ ម្យ៉ាងទៀត ៧៧% នៃអ្នកឆ្លើយសម្ភាសន៍បានប្រាប់ថា ប្រាក់ចំណូលរបស់ពួកគេយ៉ាងហោចណាស់ ក៏អាចដោះស្រាយការចំណាយប្រចាំថ្ងៃដែលមានប្រហែល ៥១% នៃប្រាក់ចំណូលនេះ។

ប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់អ្នកជាក់ស៊ីក្លូ ធ្លាក់ចុះ ១,១% ធៀបនឹងឆ្នាំមុន មកត្រឹម ១០.៥៧២រៀល។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នា ជាអ្នករកចំណូលចម្បងក្នុងគ្រួសារ។ ពួកគេសុទ្ធតែចេញពីខេត្តមករស់នៅក្រុងភ្នំពេញ ហើយភាគច្រើនមកពីខេត្តស្វាយរៀង និងខេត្តតាកែវ។ ក្នុងចំណោមពួកគេ មានតែ ១៨% ប៉ុណ្ណោះដែលស្នាក់នៅផ្ទះជួលរួមគ្នាជាមួយអ្នកជាក់ស៊ីក្លូខ្លះទៀត ហើយចូលលុយគ្នាបង់ថ្លៃឈ្នួលផ្ទះ។ អ្នកជាក់ស៊ីក្លូចំណាយជាមធ្យមអស់ ៨១% នៃប្រាក់ចំណូលសរុបរបស់ខ្លួន។

ប្រាក់ចំណូលប្រចាំថ្ងៃរបស់អ្នកលីសែងកើន ១៣% ដល់ ១៤.០៧១រៀល ឬ ៩,៧% ខ្ពស់ជាងក្នុងអង្កេតកាលពីខែឧសភា។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាស្នាក់នៅផ្ទះជួល និងចូលលុយគ្នាបង់ឈ្នួលផ្ទះ អស់ជាមធ្យម ៥ដុល្លារ/នាក់/ខែ។ អ្នកឆ្លើយសម្ភាសន៍ ៣៣% មករស់នៅក្រុងភ្នំពេញជាមួយគ្រួសាររបស់ខ្លួន។ ពួកគេមានចំណាយប្រចាំថ្ងៃអស់ដល់ ៧២% នៃប្រាក់ចំណូលរបស់ខ្លួន។

អ្នកលក់បន្លែតូចតាចគឺជា ប្រភពប្រាក់ចំណូលចម្បងសម្រាប់គ្រួសាររបស់ខ្លួន។ ចំណូលរបស់ពួកគេបានប្រសើរឡើង បើធៀបនឹងឆ្នាំមុន ប៉ុន្តែធ្លាក់ចុះ ១,៣% ធៀបនឹងខែឧសភា។ អ្នកលក់បន្លែតូចតាច មានចំណាយប្រចាំថ្ងៃស្មើនឹង ៧២% នៃប្រាក់ចំណូលរបស់ខ្លួន។

ចំណូលប្រចាំថ្ងៃរបស់កម្មករសំណង់គ្មានជំនាញកើន ២១% ធៀបនឹងឆ្នាំមុន ដល់ ១២.៩៤៤រៀលប៉ុន្តែធ្លាក់ចុះ ៥,៧% ធៀបនឹងក្នុងអង្កេតលើកមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាសុទ្ធតែមកពីខេត្ត ក្នុងនេះមាន ៧៨% បានជួលផ្ទះស្នាក់នៅ។ ពួកគេមានចំណាយប្រចាំថ្ងៃស្មើនឹង ៥៨% នៃប្រាក់ចំណូលរបស់ខ្លួន ហើយពុំមានលទ្ធភាពសន្សំប្រាក់ទុកទេ។

អ្នករត់ម៉ូតូឌុបចំនួន ៩០% ជាអ្នកមកពីតាមខេត្ត។ ពួកគេរកចំណូលបានជាមធ្យម ១៣.៥៧៣រៀល/ថ្ងៃ ឬកើន ០,៦% ធៀបនឹងឆ្នាំមុន និង ៨,៤% ធៀបនឹងខែឧសភា។ សម្រាប់ ៩៧% នៃអ្នកឆ្លើយសម្ភាសន៍ ប្រាក់ចំណូលនេះអាចដោះស្រាយការចំណាយប្រចាំថ្ងៃបាន។

អ្នករត់តុភោជនីយដ្ឋានរកចំណូលបាន ៦៧៥០រៀល/ថ្ងៃ ឬកើន ២១% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ អ្នកឆ្លើយសម្ភាសន៍ទាំងអស់គ្នាសុទ្ធតែមកពីតាមខេត្ត ហើយម្ចាស់ភោជនីយដ្ឋានបានផ្តល់កន្លែងឲ្យស្នាក់នៅ។ ក្នុងចំណោមពួកគេ មាន ៧៥% ជាប្រភពប្រាក់ចំណូលដ៏សំខាន់ក្នុងគ្រួសារ។ ពួកគេមិនមានលទ្ធភាពសន្សំប្រាក់ទុកទេ។

ប្រាក់ចំណូលរបស់កម្មករកាត់ដេរកើន ៧,៩% ធៀបនឹងឆ្នាំមុន ដល់ ១០.៣៥៧រៀល/ថ្ងៃ។ គ្មានកម្មករឆ្លើយសម្ភាសន៍ណាម្នាក់បានបញ្ចប់ការអប់រំថ្នាក់បឋមសិក្សានោះឡើយ។ ទោះជាយ៉ាងនេះក្តី ក៏មាន ១៩% បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលជំនាញមុននឹងទទួលបានការងារនៅក្នុងរោងចក្រ។ ពួកគេធ្វើការ ៦ថ្ងៃ មានសរុប ៥៨ម៉ោង ក្នុងមួយសប្តាហ៍។ ជាមួយប្រាក់ចំណូលនេះ ពួកគេមិនអាចទ្រទ្រង់ជីវភាពគ្រួសារនៅឯស្រុកបានគ្រប់គ្រាន់ទេ។

## តារាង ១. គម្រោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០៦-១៣*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | |
| កសិកម្ម | 498.0 | 135.6 | 92.0 | 615.0 | 530.68 | 725 | 154.7 | 81.2 | 181.1 | 114.6 | 2.3 | 56.8 |
| ឧស្សាហកម្ម | 365.3 | 709.1 | 724.9 | 818.5 | 403.66 | 2860.1 | 208.7 | 173.7 | 245.6 | 196.5 | 195.4 | 1928.3 |
| *កាត់ដេរ* | *89.4* | *170.7* | *142.8* | *90.1* | *122.81* | *393.9* | *139.4* | *97.5* | *107.2* | *152.9* | *109.5* | *76.4* |
| សេវាកម្ម | 2939.1 | 1742.5 | 10,003.2 | 4432.0 | 1337.34 | 3425.4 | 50.9 | 18.0 | 2.1 | 845.6 | 21.2 | 106.0 |
| *សណ្ឋាគារ និងទេសចរណ៍* | *345.0* | *1048.3* | *8758.1* | *3980.1* | *1105.14* | *2850.9* | *50.9* | *0.0* | *0.0* | *640.6* | *0.0* | *106.0* |
| សរុប | 3802.4 | 2587.2 | 10,570.9 | 5865.5 | 2271.7 | 7010.42 | 414.4 | 273.0 | 428.8 | 1156.6 | 218.9 | 2091.1 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | -69 | -33.9 | 55.6 | 169.8 | -81.1 | 855.5 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | 275.6 | 246.6 | 308.6 | -44.5 | -61.3 | 209 | 48.4 | -89.6 | -84.4 | -13.6 | -47.5 | 666.0 |

* Including expansion project approvals. Source: Cambodian Investment Board

## តារាង ២. តម្លៃគម្រោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ភូមិគ្រឹះ និងផ្ទះ | 33.1 | 79.1 | 154.7 | 64.3 | 36.2 | 185.5 | 64.8 | 66.6 | 18.3 | 8.5 | 145.2 | 10.3 |
| ផ្ទះល្វែង | 213.3 | 297.2 | 221.6 | 149.6 | 183.8 | 219.6 | 60.8 | 219.3 | 61.6 | 10.2 | 114.1 | 33.0 |
| ផ្សេងៗ | 76.8 | 259.6 | 740.9 | 227.3 | 269.7 | 199.9 | 197.2 | 47.8 | 94.9 | 41.2 | 154.4 | 238.3 |
| សរុប | 323.3 | 635.8 | 1117.0 | 441.2 | 489.8 | 605.0 | 322.8 | 333.6 | 174.9 | 59.9 | 443.7 | 281.6 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 117.1 | 3.3 | -47.6 | -65.8 | 590.9 | -36.5 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.9 | 96.7 | 75.7 | -60.5 | 11 | 23.5 | 637.1 | 331.1 | -29.3 | -59.7 | 28.1 | -15.6 |

Source: Department of Cadastre and Geography of Phnom Penh municipality

## តារាង ៣. ចំនួនអ្នកដំណើរបរទេសមកដល់ប្រទេសកម្ពុជា ឆ្នាំ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | |
| តាមផ្លូវអាកាស | 33.1 | 79.1 | 1239.4 | 1111.7 | 1304.3 | 1480.4 | 513.6 | 317.1 | 370.5 | 500.7 | 611.2 | 398.1 |
| តាមផ្លូវគោក និងទឹក | 213.3 | 297.2 | 881.9 | 999.7 | 1094.6 | 14014.6 | 481.5 | 424.3 | 450.3 | 506.1 | 560.9 | 522.5 |
| សរុប | 76.8 | 259.6 | 2121.3 | 2111.5 | 2398.9 | 28818.6 | 995.2 | 761.4 | 820.9 | 1006.8 | 1172.1 | 920.5 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | |
| សរុប | - | - | - | - | - | - | 24.9 | -23.5 | 7.8 | 22.6 | 16.4 | -21.5 |
| | | | | | | | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | |
| សរុប | -9.9 | 96.7 | 5.3 | 0.5 | 13.6 | 20.1 | 27.8 | 25.5 | 17.3 | 26.3 | 17.8 | 20.9 |

Source: Ministry of Tourism

## តារាង ៤. ការនាំចេញ និងនាំចូល ឆ្នាំ២០០៦-១៣*

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 Q1 | Q2 | Q3 | Q4 | 2013 Q1 | Q2 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | លានដុល្លារ | | | | | |
| ការនាំចេញសរុប | 2922.8 | 3161.6 | 3097.8 | 2901.6 | 3630.2 | 4929.5 | 1280.1 | 1775.9 | 1595.8 | 1454.7 | 1576.9 | 1620.1 |
| ក្នុងនេះ៖ សម្លៀកបំពាក់ | 2810.8 | 3050.2 | 2986.2 | 2565.3 | 3223.4 | 4259.6 | 1070.8 | 1474.7 | 1329.1 | 1140.83 | 1225.2 | 1258.95 |
| *- សហរដ្ឋអាមេរិក* | 1851.7 | 1959.9 | 1908.3 | 1512.6 | 1853.9 | 2055.3 | 493.3 | 627.3 | 566.6 | 456.07 | 526.8 | 474.62 |
| *- សហភាពអឺរ៉ុប* | 603.0 | 660.9 | 689.0 | 644.7 | 809.5 | 1322.2 | 328.4 | 504.1 | 462.7 | 421.82 | 397.5 | 477.47 |
| *- អាស៊ាន* | 80.4 | 90.3 | 10.76 | 6.9 | 9.9 | 17.63 | 6.4 | 11.7 | 11.4 | 9.76 | 13.0 | 12.66 |
| *- ជប៉ុន* | 40.6 | 30.1 | 25.2 | 44.5 | 86.5 | 146.97 | 50.1 | 48.9 | 47.1 | 42.47 | 57.6 | 51.39 |
| *- ប្រទេសផ្សេងៗ* | 235.1 | 309.0 | 352.9 | 356.5 | 463.6 | 717.5 | 192.5 | 282.7 | 241.3 | 210.71 | 230.3 | 242.81 |
| កសិកម្ម | 59.7 | 55.6 | 44.5 | 73.1 | 164.9 | 362.05 | 80.5 | 101.3 | 86.1 | 108.77 | 123.8 | 128.9 |
| *- កៅស៊ូ* | 41.5 | 41.0 | 35.8 | 51.6 | 89.1 | 197.63 | 40.3 | 46.4 | 46.1 | 43.84 | 36.6 | 38.67 |
| *- ឈើ* | 8.6 | 8.7 | 3.4 | 3.5 | 34.1 | 48.79 | 8.9 | 12.4 | 4.1 | 11.6 | 14.5 | 8.88 |
| *- ត្រី* | 5.9 | 3.2 | 2.3 | 3.9 | 2.8 | 3.12 | 0.5 | 0.7 | 0.4 | 0.4 | 0.3 | 0.5 |
| *- ស្រូវ* | 3.7 | 2.7 | 2.6 | 10.9 | 34.7 | 106.56 | 27.1 | 37.5 | 31.7 | 50.2 | 65.8 | 56.47 |
| *- ផលិតផលកសិកម្មផ្សេងៗ* | 52.3 | 55.8 | 0.5 | 3.0 | 4.1 | 5.95 | 3.9 | 4.4 | 3.9 | 2.8 | 6.6 | 24.41 |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផ្សេងៗ | 512.2 | 554.8 | 67.1 | 263.22 | 242.0 | 307.86 | 128.8 | 199.9 | 180.6 | 205.1 | 274.9 | 232.24 |
| ការនាំចូលសរុប | 38.8 | 58.7 | 4272.5 | 4331.5 | 5190.6 | 6375.9 | 1609.2 | 1885.4 | 2015.2 | 1938.2 | 1576.9 | 2211.4 |
| ក្នុងនេះ៖ សាំង | 113.0 | 122.8 | 84.8 | 91.13 | 108.6 | 294.4 | 70.7 | 76.7 | 78.0 | 78.8 | 1225.2 | 77.19 |
| ម៉ាស៊ូត | 56.5 | 69.0 | 19.5 | 180.67 | 203.8 | 447 | 139.4 | 126.6 | 138.3 | 139.9 | 526.8 | 137.44 |
| សម្ភារៈសំណង់ | 303.9 | 304.3 | 56.3 | 49.74 | 57.6 | 48.09 | 13.5 | 14.1 | 16.5 | 16.6 | 397.5 | 17.75 |
| ផ្សេងៗ | 2410.6 | 2606.8 | 4011.8 | 4010 | 4820.6 | 5586.4 | 1386 | 1668.0 | 1782.4 | 1703.0 | 13.0 | 1979 |
| ជញ្ជីងពាណិជ្ជកម្ម | 2922.8 | 3161.6 | -1174.7 | -1429.9 | -1560.5 | -1446.4 | -329.1 | -642.2 | -419.4 | -483.6 | -1606.68 | -591.24 |
| | បម្រែបម្រួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | - | - | - | - | - | - | -5.2 | -37.7 | -9.9 | -14.2 | 7.4 | 2.8 |
| ការនាំចេញសរុប | - | - | - | - | - | - | -3.3 | 38.7 | -10.1 | -8.8 | 8.4 | 2.7 |
| ការនាំចូលសរុប | - | - | - | - | - | - | -6.0 | 17.2 | 6.9 | -3.8 | 13.1 | 0.9 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសម្លៀកបំពាក់សរុប | 19.5 | 8.5 | 1.6 | -14.1 | 25.7 | 32.1 | 21.6 | 53.0 | 3.4 | 1.0 | 14.4 | -14.6 |
| ការនាំចេញសរុប | 19.2 | 8.2 | 1.6 | -6.3 | 25.1 | 35.8 | 25.8 | 56.9 | 9.6 | 9.9 | 23.2 | -8.8 |
| ការនាំចូលសរុប | -79.6 | 8.3 | 1.3 | 1.4 | 19.8 | 22.8 | 10.6 | 11.6 | 32.7 | 13.2 | 36.2 | 17.8 |

* Import data include tax-exempt imports. Sources: Department of Trade Preference Systems, MOC and Customs and Excise Department, MEF (web site)

## តារាង ៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានសាច់ប្រាក់ ឆ្នាំ២០០៦-១៣ (ពាន់លានរៀល)

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| ចំណូលសរុប | 3259.2 | 1146.1 | 5290.0 | 5988.99 | 2805.83 | 6251.4 | 1728.9 | 2045.1 | 1900.8 | 2017.0 | 1820.2 | 2204.8 |
| ចំណូលចរន្ត | 2881.8 | 1141.6 | 5210.7 | 5859.08 | 2786.12 | 6179.3 | 1725.8 | 1928.6 | 1796.4 | 1993.1 | 1814.3 | 2193.3 |
| ចំណូលពន្ធ | 2270.9 | 965.2 | 4409.9 | 4692.96 | 2457.02 | 5277.5 | 1403.82 | 1721.8 | 1560.7 | 1648.5 | 1575.3 | 2024.1 |
| ពន្ធក្នុងស្រុក | - | 661.8 | 3248.4 | 3533.57 | 1727.10 | 4071.6 | 1092.27 | 1403.4 | 1230.0 | 1277.2 | 1253.1 | 1653.0 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | 303.5 | 1161.5 | 1159.39 | 639.00 | 1205.9 | 311.253 | 318.4 | 330.7 | 371.4 | 322.3 | 371.1 |
| ចំណូលមិនមែនពន្ធ | 610.9 | 176.4 | 800.8 | 1166.13 | 507.13 | 901.8 | 330.98 | 206.9 | 235.7 | 344.6 | 239.0 | 169.2 |
| ចំណូលលើទ្រព្យសម្បត្តិ | - | 13.6 | 78.0 | 291.13 | 4.87 | 63.8 | 91.28 | 13.1 | 22.5 | 16.2 | 8.2 | 18.1 |
| លក់ទំនិញ និងសេវា | - | 124.3 | 424.7 | 460.07 | 268.08 | 588.7 | 166.899 | 171.4 | 132.8 | 196.3 | 152.8 | 137.0 |
| ចំណូលមិនមែនពន្ធផ្សេងទៀត | - | 38.5 | 298.2 | 408.91 | 391.70 | 249.3 | 63.8 | 22.4 | 80.5 | 132.1 | 78.0 | 14.0 |
| ចំណូលជាមូលធន | 377.4 | 4.5 | 79.3 | 129.92 | 2019.39 | 72.1 | 3.148 | 116.4 | 104.4 | 23.9 | 5.9 | 11.5 |
| ចំណាយសរុប | 4174.7 | 1689.7 | 6297.8 | 8784.65 | 4259.67 | 9032.4 | 1688.33 | 2425.6 | 2951.3 | 2751.5 | 925.9 | 1925.7 |
| ចំណាយជាមូលធន | 1638.1 | 807.4 | 2574.4 | 2853.23 | 1495.19 | 3546.9 | 699.937 | 716.2 | 1194.5 | 1017.7 | 146.3 | 239.8 |
| ចំណាយចរន្ត | 2536.8 | 882.3 | 3809.0 | 4773.07 | 2848.81 | 5341.2 | 988.398 | 1709.4 | 1756.7 | 1733.9 | 879.6 | 1685.8 |
| បៀវត្សរ៍ | 822.0 | 362.6 | 1397.0 | 2048.81 | 1208.81 | 2170.6 | 508.919 | 725.2 | 657.5 | 595.0 | 395.3 | 590.2 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | 194.2 | 927.1 | 1099.42 | 613.31 | 1518.8 | 189.594 | 514.6 | 462.1 | 420.5 | 247.4 | 642.5 |
| ចំណាយចរន្តផ្សេងទៀត | - | 325.5 | 1384.9 | 1624.84 | 1067.07 | 1651.8 | 289.9 | 469.7 | 637.1 | 718.4 | 236.9 | 453.2 |
| សមតុល្យជាទូទៅ | -915.6 | -543.6 | -1007.8 | -2795.66 | -1453.83 | -1271.4 | 196.5 | -380.6 | -1050.5 | -734.5 | 0.0 | 279.2 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1360.7 | 741.5 | 2055.10 | 1845.21 | 772.81 | -2781.0 | 577.8 | 491.5 | 959.3 | 429.2 | 894.4 | 129.0 |
| ហិរញ្ញប្បទានក្នុងស្រុក | -445.1 | -185.8 | -127.00 | 938.64 | 567.96 | 2379.2 | -565.7 | 148.4 | 22.1 | 62.4 | -44.2 | 0.0 |

Source: MEF web site

## តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្ដូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ២០០៦-១៣

| | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | Q1 | Q2 | Q3 | Q4 | Q1 | Q2 |
| (តុលា-ធ្នូ ២០០៦:១០០) | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ភ្នំពេញ - ទំនិញគ្រប់មុខ | 4.7 | 5.8 | 19.7 | -0.7 | 4.1 | 5.4 | 2.9 | 2.9 | 1.6 | 1.8 | 1.5 | 2.2 |
| - ស្បៀងអាហារ និងភេសជ្ជៈគ្មានជាតិស្រា | 6.4 | 9.9 | 33.1 | -0.3 | 4.4 | 6.5 | 3.4 | 3.4 | 1.3 | 1.4 | 1.7 | 2.7 |
| - ដឹកជញ្ជូន | 9.1 | 5.8 | 19.4 | -10.7 | 7.0 | 6.9 | 3.0 | 3.0 | 1.1 | 1.2 | -0.8 | -1 |
| | អត្រាប្ដូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 4119.0 | 4062.7 | 4058.2 | 4140.5 | 4187.1 | 4063.6 | 4046.0 | 4054.3 | 4060.7 | 3995.9 | 3995 | 4033.1 |
| រៀលក្នុង ១ បាតថៃ | 108.7 | 122.8 | 123.5 | 121.1 | 133.13 | 133.2 | 130.2 | 129.0 | 129.3 | 131.3 | 134.7 | 135.74 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.1 | 25.0 | 24.8 | 23.4 | 21.725 | 19.7 | 19.3 | 19.4 | 19.5 | 19.2 | 19.3 | 19.34 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 70.6 | 83.2 | 105.9 | 113.1 | 147.58 | 184.5 | 204.1 | 194.5 | 198.3 | 206.5 | 197.1 | 196 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 3140.0 | 3262.3 | 4555.2 | 3170.9 | 3859.3 | 4761.2 | 5193.9 | 4458.3 | 4983.9 | 5128.8 | 5134.4 | 4992 |
| ថ្លៃសាំង (រៀល/លីត្រ) | 4004.0 | 4005.0 | 4750.8 | 3593.1 | 4368.1 | 5044.5 | 5395.8 | 5308.3 | 5251.3 | 5295.4 | 5410.5 | 5274.5 |

Sources: NIS, NBC and CDRI

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០៥-១២ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2005 | 2006 | 2007 | 2008 | 2009 | 2010 | 2011 | 2012 | | | | 2013 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 5475.0 | 7224.0 | 10,735.0 | 10,345.0 | 14,655.0 | 16,697.9 | 17893.9 | 18,652.3 | 18,729.6 | 18,463.8 | 18,154.5 | 19,976.7 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -450.0 | -282.0 | 576.0 | 1513.3 | 1573.0 | 2778.9 | | 6211.2 | 7922.3 | 8400.3 | 10437.4 | 10,504.1 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -421.0 | -953.0 | -1816.0 | -2987.0 | -2252.0 | -2126.6 | -2123.1 | -2542.4 | -2399.9 | -2440.6 | -2486.4 | -2991.6 |
| ឥណទានដល់ផ្នែកឯកជន | 2394.0 | 3630.0 | 6386.0 | 9894.0 | 10,532.0 | 13,331.2 | 17552.8 | 18,789.0 | 20,081.4 | 21,398.2 | 23,536.6 | 24,820.2 |
| រូបិយវត្ថុទូទៅ M2 | 5025.0 | 6942.0 | 11,311.0 | 11,858.0 | 16,228.0 | 19,476.8 | 23654.7 | 24,863.5 | 26,651.9 | 26,864.1 | 28,591.9 | 30,480.8 |
| រូបិយវត្ថុ M1 | 1323.0 | 1658.0 | 2052.0 | 2399.0 | 3120.0 | 3220.9 | 3956.2 | 3984.6 | 3871.8 | 3818.2 | 4045.7 | 4500.6 |
| រូបិយវត្ថុផ្សេងៗ | 3702.0 | 5285.0 | 9259.0 | 9459.0 | 13,108.0 | 16,255.9 | 19698.5 | 20,878.9 | 22,780.1 | 23,046.0 | 24,546.2 | 25,980.2 |
| | បម្រែបម្រួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.1 | 38.1 | 62.9 | 4.8 | 36.9 | 20.0 | 17.8 | 20.2 | 21.1 | 18.6 | 20.9 | 22.6 |
| រូបិយវត្ថុ M1 | 14.7 | 25.3 | 23.8 | 16.9 | 30.1 | 3.2 | 16.9 | 11.4 | 9.4 | 3.7 | 2.3 | 12.9 |
| រូបិយវត្ថុផ្សេងៗ | 16.6 | 42.8 | 75.2 | 2.2 | 38.6 | 24.0 | 17.9 | 22.0 | 23.4 | 21.5 | 44.6 | 24.4 |

Source: National Bank of Cambodia

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បម្រែបម្រួលជាភាគរយធៀបឆ្នាំមុន | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2008 | 2009 | 2010 | 2011 | 2012 | | 2013 | | | 2013 | | |
| | | | | | សីហា | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | កុម្ភៈ | ឧសភា | សីហា |
| អ្នកបាក់ស៊ីក្លូ | 12,628 | 8091 | 9055 | 9532 | 10690 | 10454 | 9588 | 10,681 | 10,572 | 2.2 | -0.0 | -1.1 |
| អ្នកលីសែង | 9005 | 9549 | 9964 | 10,785 | 12,479 | 12,574 | 12,744 | 12,823 | 14,071 | 18.0 | 0.9 | 12.8 |
| អ្នកលក់បន្លែតូចតាច | 9926 | 8273 | 8266 | 8337 | 10,347 | 10,542 | 9949 | 11,571 | 11,421 | -19.1 | 16.9 | 10.4 |
| អ្នករើសអេតចាយ | 4652 | 5857 | 6698 | 8388 | 9139 | 9328 | 9483 | 10,440 | 9561 | 18.7 | 26.3 | 4.6 |
| អ្នកបម្រើតុភោជនីយដ្ឋាន* | 4327 | 4646 | 5607 | 5986 | 5569 | 6436 | 6527 | 6744 | 6750 | 5.6 | 7.7 | 21.2 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 8697 | 6197 | 5691 | 5695 | 8483 | 5000 | 5828 | 6427 | 7723 | 23.8 | -0.1 | -9.0 |
| កម្មកររោងចក្រកាត់ដេរ | 6554 | 7085 | 7746 | 8409 | 9599 | 8989 | 10,000 | 9776 | 10,357 | 16.9 | 13.6 | 7.9 |
| អ្នករត់ម៉ូតូឌុប | 15,691 | 10,685 | 10,623 | 11,568 | 12,807 | 13,042 | 14,427 | 12,522 | 13,573 | 17.7 | -8.0 | 6.0 |
| កម្មករសំណង់គ្មានជំនាញ | 8779 | 8343 | 8790 | 10,307 | 10,690 | 11,375 | 12,548 | 13,728 | 12,944 | 17.7 | 18.5 | 21.1 |
| កម្មករសំណង់មានជំនាញ | 12,710 | 12,487 | 11,952 | 13,159 | 14,029 | 14,270 | 15,156 | 14,136 | 15,726 | 9.6 | 10.0 | 12.1 |

* Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice-field workers, garment workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI

# ព័ត៌មានថ្មីៗពីវិទ្យាស្ថាន CDRI

## ព្រឹត្តិការណ៍សំខាន់ៗ

នៅដើមខែសីហា ២០១៣ វិទ្យាស្ថាន CDRI បានទៅចូលរួមការប្រជុំរបស់ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលជាការពិគ្រោះយោបល់ជាដំបូងជាមួយអ្នកពាក់ព័ន្ធនានាលើរបាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០១៤ ក្រោមប្រធានបទ វិនិយោគក្នុងការអភិវឌ្ឍធនធានមនុស្ស តាមមាគ៌ានៃកំណើនសម្រាប់គ្រប់គ្នា ដែលសង្កត់ធ្ងន់លើការចូលរួមប្រកបដោយប្រសិទ្ធភាព និងភាពជាម្ចាស់នៃស្ថាប័នក្នុងស្រុកនានា។ ក្នុងអំឡុងពេលពីខែកក្កដា ដល់ខែកញ្ញា ២០១៣ វិទ្យាស្ថាន CDRI បានប្រជុំតុមូលដើម្បីរាយការណ៍ពីការងាររបស់ CDRI និងអាទិភាពអភិវឌ្ឍន៍ចម្បងៗរបស់កម្ពុជា ជូនដល់លោកជំទាវ Alison Burrows ជាឯកអគ្គរដ្ឋទូតនៃប្រទេសអូស្ត្រាលី, លោក Paul Keogh ជាទីប្រឹក្សានៃ ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) និងលោកស្រី Claire Van der Vaeren ជាអ្នកសម្របសម្រួលប្រចាំប្រទេសនៃ អង្គការសហប្រជាជាតិ/តំណាងប្រចាំប្រទេសនៃ UNDP ។

ក្នុងការប្រជុំពាក់កណ្ដាលឆ្នាំកាលពីថ្ងៃទី២៣ សីហា ក្រុមប្រឹក្សាភិបាល CDRI បានស្វាគមន៍ការយល់ព្រមចូលជាសមាជិករបស់ខ្លួន ពីសំណាក់ឥស្សរជន ៣នាក់ថ្មីទៀត ដែលនឹងទទួលតំណែងនេះជាផ្លូវការ នៅពេលប្រជុំពេញអង្គលើកក្រោយនៃក្រុមប្រឹក្សាភិបាល CDRI នៅខែកុម្ភៈ ២០១៤ ខាងមុខ គឺមានបណ្ឌិត Suthad Setboonsarng ប្រធានមូលនិធិ NawachiOne នៅប្រទេសថៃ និងជាអតីតតំណាងពាណិជ្ជកម្មថៃ និងមន្ត្រីជាន់ខ្ពស់នៃអាស៊ាន, លោកស្រី Sandra D'Amico ជានាយកគ្រប់គ្រងនៃក្រុមហ៊ុន HR Inc Cambodia និងជាអនុប្រធាននៃសហព័ន្ធនិយោជក និងសមាគមពាណិជ្ជកម្មកម្ពុជា, និងលោកស្រី Eva Mysliwiec ជាប្រធានក្រុមប្រឹក្សាភិបាលនៃអង្គការយុវតារាកម្ពុជា និងជាអតីតនាយកស្ថាបនិកនៃ CDRI ។

កាលពីខែកញ្ញា នាយកប្រតិបត្តិនៃ CDRI បានទៅចូលរួមក្នុង (១) វេទិកាអន្តរជាតិស្ដីពី ភាពតភ្ជាប់នៃអាស៊ានបូកបី ដើម្បីសមាហរណកម្មនៅអាស៊ីបូព៌ា: គោលគំនិត និងការប្រមើលឃើញ។ វេទិកានេះរៀបចំឡើងដោយ វិទ្យាស្ថានជាតិនៃយុទ្ធសាស្ត្រអន្តរជាតិ (NIIS) នៃបណ្ឌិតសភាវិទ្យាសាស្ត្រសង្គមចិន (CASS) នៅក្រុងប៉េកាំង ហើយលោកនាយក CDRI បានធ្វើបទបង្ហាញមួយស្ដីពី ភាពតភ្ជាប់នៃអាស៊ានបូកបី: ផលប្រយោជន៍សម្រាប់កម្ពុជា និងមហាអនុតំបន់មេគង្គ (GMS) និង

(២) វេទិកាវិទ្យាស្ថានអាស៊ីបូព៌ាលើកទី៩ ស្ដីពី សមាហរណកម្មសេដ្ឋកិច្ចអាស៊ីបូព៌ា និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ដែលរួមសហការរៀបចំដោយ វិទ្យាស្ថានកូរ៉េសម្រាប់គោលនយោបាយសេដ្ឋកិច្ចអន្តរជាតិ (KIEP) និង មជ្ឈមណ្ឌលតណ្ឌនេស៊ីសម្រាប់ការសិក្សាជាយុទ្ធសាស្ត្រ និងអន្តរជាតិ (CSIS) នៅក្រុងហ្សាកាតា ដោយបានធ្វើបទបង្ហាញមួយស្ដីពី RCEP អាចជួយយ៉ាងណាបានដល់ កម្ពុជា-ឡាវ-មីយ៉ាន់ម៉ា-វៀតណាម (CLMV): ជម្រើសនានា និងបញ្ហាចោទ។

នៅថ្ងៃទី២៥-២៧ ខែកញ្ញា ដោយរួមសហការជាដៃគូជាមួយវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ (IFPRI) និងក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD), វិទ្យាស្ថាន CDRI បានរៀបចំនៅឯខេត្តសៀមរាបនូវសិក្ខាសាលាថ្នាក់តំបន់អាស៊ីស្ដីពី ការកែប្រែកសិកម្មនៅអាស៊ីៈ ជម្រើសគោលនយោបាយសម្រាប់ស្បៀង និងសន្តិសុខអាហារូបត្ថម្ភ ដែលមានអ្នកចូលរួម ១៤០នាក់ មកពីអាស៊ីបូព៌ា អាស៊ីខាងត្បូង និងអាស៊ីកណ្ដាល ដោយមានការឧបត្ថម្ភគាំទ្រពី ជំនួយអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID)។

## ផ្នែកស្រាវជ្រាវ

### កម្មវិធីអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ និងកំណែទម្រង់វិស័យសាធារណៈ (DGPSR)

គម្រោងចំនួនប្រាំបួន កំពុងដំណើរការទៅមុខ។ គម្រោងស្រាវជ្រាវបី បានចប់សព្វគ្រប់ និងកំពុងរៀបចំបោះពុម្ពផ្សាយជាឯកសារពិភាក្សា ក្នុងនោះមាន របាយការណ៍ស្ដីពី "វិមជ្ឈការបែបប្រជាធិបតេយ្យ និងយេនឌ័រៈ ការវិភាគពីយេនឌ័រក្នុងគណបក្សនយោបាយនៅកម្ពុជា" និងអត្ថបទពីរស្ដីពីសង្គមស៊ីវិល គឺមាន "សង្គមស៊ីវិលថ្នាក់ក្រោមជាតិនៅកម្ពុជាៈ ការវិភាគតាមទស្សនៈ Gramsci" និង "ម្ភៃឆ្នាំបន្ទាប់ពីអាជ្ញាធរអ៊ុនតាក់ៈ តើសង្គមស៊ីវិលកម្ពុជាបានរឹងមាំឡើងឬទេ?"

គម្រោងចំនួនបួនកំពុងស្ថិតក្នុងដំណាក់កាលប្រមូលទិន្នន័យ។ ការសម្ភាសអ្នកផ្ដល់ព័ត៌មានគន្លឹះនៅថ្នាក់មូលដ្ឋាន និងថ្នាក់ជាតិបានអនុវត្តរួចហើយសម្រាប់គម្រោង "តួនាទីកំពុងផុសឡើងរបស់យុវជន នៅក្នុងសកម្មភាពនយោបាយ និងសេដ្ឋកិច្ច"។ សម្រាប់គម្រោង "ការតភ្ជាប់អភិបាលកិច្ចមូលដ្ឋាន ទៅនឹង ការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម" ក្រុមស្រាវជ្រាវបានជូនរបាយការណ៍សិក្សាលើឯកសារមានស្រាប់ ទៅឲ្យម្ចាស់ជំនួយរួចរាល់ និងកំពុងចុះសិក្សាដល់កន្លែងនៅកម្រិតជាតិ។ ការសិក្សាដល់កន្លែងបានអនុវត្តចប់រួចរាល់ សម្រាប់គម្រោង "រដ្ឋកម្ពុជាៈ តើមានលក្ខណៈល្អយ៉ាងណាសម្រាប់ការអភិវឌ្ឍ?" ដែលប្រើប្រាស់នូវគំរូរដ្ឋសម្រាប់អភិវឌ្ឍន៍ ដើម្បីវាយតម្លៃពីផលប៉ះពាល់នៃកំណែទម្រង់អភិបាលកិច្ច ទៅលើសមត្ថភាពស្ថាប័នរបស់រដ្ឋក្នុងការជំរុញការអភិវឌ្ឍ, និងអនុវត្តរួចរាល់ដែរសម្រាប់គម្រោង "ដំណោះស្រាយនយោបាយ និងកំណើនសម្រាប់គ្រប់គ្នានៅកម្ពុជា" ដែលជាផ្នែកមួយនៃការសិក្សាពហុប្រទេសមានប្រើប្រាស់នូវការវិភាគពីដំណោះស្រាយនយោបាយ ដើម្បីស្វែងយល់ពីល្បឿន លក្ខណៈសម្រាប់គ្រប់គ្នា និងចីរភាពនៃការអភិវឌ្ឍរបស់ប្រទេសនីមួយៗ។

គម្រោងចំនួនពីរ ជិតចប់រួចរាល់។ របាយការណ៍ទី២ ស្ដីពី "រឿងល្អទាំងអស់ មិនមែនសុទ្ធតែដើរស្របគ្នានោះទេៈ ការវិភាគពីភាពប្រទាំងប្រទើសគ្នារវាង ការកសាងសន្តិភាព និងប្រជាធិបតេយ្យភាវូបនីយកម្ម" ដែលជាគម្រោងអនុវត្តឡើងក្រោមកិច្ចសហការជាដៃគូជាមួយ សាកលវិទ្យាល័យ Gothenburg ដើម្បីកំណត់ពីបែបបទ និងមូលហេតុ ដែលទំនាស់ផុសឡើងក្នុងរយៈពេលខ្លី និងវែង បន្ទាប់ពីមាន ឬក៏អាចកើតឡើងពី អន្តរាគមន៍ខាងកសាងសន្តិភាពនោះ ក្រុមស្រាវជ្រាវកំពុងចងក្រងបញ្ចប់ដើម្បីបោះពុម្ពផ្សាយ។ សម្រាប់គម្រោង "អភិបាលកិច្ចតំបន់ទីក្រុងនៅកម្ពុជាក្រោយធ្វើវិមជ្ឈការ" ក្រុមស្រាវជ្រាវកំពុងចងក្រងបញ្ចប់របាយការណ៍ទី១ ដោយផ្អែកលើមតិយោបល់ទទួលបានពីទីប្រឹក្សាស្រាវជ្រាវ និងត្រៀមចងក្រងនូវរបាយការណ៍ទី២ ទៀត។

### កម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ (ETRC)

"អង្កេតប្រចាំត្រីមាសលើពលករងាយរងគ្រោះ" ដើម្បីបានព័ត៌មានពីប្រាក់ចំណូលជាមធ្យមរបស់ពលករក្រីក្រ ចំនួន ១០ក្រុម នៅតំបន់ទីក្រុង និង "អង្កេតប្រចាំខែលើថ្លៃទំនិញតាមខេត្ត" នៅក្នុង ១២ខេត្ត មានដំណើរការទៅមុខល្អ។ ឯកសារពិភាក្សាស្ដីពី "ការលើកកម្ពស់ពាណិជ្ជកម្មដើម្បីកំណើនសេដ្ឋកិច្ចនៅកម្ពុជា" ដែលជាសមាសភាគមួយនៃគម្រោងស្រាវជ្រាវរយៈពេលប្រាំឆ្នាំ ក្រោមជំនួយទ្រទ្រង់ពី Sida នោះ បានបោះពុម្ពផ្សាយរួចហើយ។

ការសិក្សាចំនួនបី គឺៈ "ភាពអំណោយផលដល់ជនក្រីក្រនៃគោលនយោបាយហិរញ្ញវត្ថុ-ចំណាយលើការអប់រំ" "គោលនយោបាយទីផ្សារពលកម្ម" និង "កំណើនសេដ្ឋកិច្ច វិសមភាព និងការកាត់បន្ថយភាពក្រីក្រ" កំពុងស្ថិតក្នុងដំណាក់កាលវិភាគ និងបកស្រាយទិន្នន័យ។ របាយការណ៍ព្រាងដំបូងស្ដីពី "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជាៈ មូលហេតុ និងផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" ដែលជាការសិក្សាទទួលបានមូលនិធិពី អង្គការភាពជាដៃគូដើម្បីសិក្សាពីគោលនយោបាយសេដ្ឋកិច្ច (PEP) បានបញ្ជូនរួចរាល់ទៅឲ្យទីប្រឹក្សាគម្រោងដើម្បីសុំមតិយោបល់ ហើយបច្ចុប្បន្នកំពុងចងក្រងបញ្ចប់។ របាយការណ៍សម្រេចស្ដីពី "ការពិនិត្យពីបរិបទសម្រាប់របាយការណ៍ប្រចាំឆ្នាំ (MERV)" និង "ការវាយតម្លៃពីបរិបទអភិវឌ្ឍន៍នៅតំបន់មេគង្គ/បណ្ដាប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម" ខាងទីភ្នាក់ងារស្វ៊ីសដើម្បីកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍន៍ (SDC) បានទទួលយកហើយ។ អង្កេតគ្រួសារ និងអង្កេតសហគ្រាស សម្រាប់ការសិក្សាស្ដីពី "ការប្រើប្រាស់ប្រាក់ដុល្លារអាមេរិកនៅកម្ពុជា" ដែលធ្វើឡើងសម្រាប់ ការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចនៃអាស៊ានបូកបី (AMRO) បានចប់រួចរាល់។ គម្រោងស្រាវជ្រាវពី "ទំនាក់ទំនងរវាង គោលនយោបាយសាធារណៈរបស់បណ្ដាប្រទេសជាដៃគូ ចំណាកស្រុក និងការអភិវឌ្ឍៈ ករណីសិក្សា និងអនុសាសន៍ផ្នែកនយោបាយ" បានចាប់ផ្ដើម និងគ្រោងដំណើរការរហូតដល់ចុងឆ្នាំ២០១៥ ដោយទទួលបានមូលនិធិពី អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងការ

អភិវឌ្ឍ (OECD)។

ក្នុងឋានៈជាអ្នកសម្របសម្រួល បណ្ដាញវិភាគអភិវឌ្ឍន៍មហាអនុតំបន់មេគង្គ (GMS DAN) ក្រុមស្រាវជ្រាវប្រចាំកម្មវិធី ETRC បានចងក្រង និងធ្វើនូវឯកសារគោលគំនិតស្ដីពី "ទីផ្សារពលកម្មកង្វះខាតផ្នែកជំនាញ និងលំហូរកម្លាំងពលកម្មនៅមហាអនុតំបន់មេគង្គ៖ ផលពាក់ព័ន្ធនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន (DAN 9 Stage II)" ព្រមទាំងឯកសារគម្រោងថវិកា ទៅឲ្យមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្ដរជាតិ (IDRC) ដើម្បីពិនិត្យមើល។ សៀវភៅក្នុងកម្រងការសិក្សាពីការអភិវឌ្ឍនៅ មហាអនុតំបន់មេគង្គមានចំណងជើងថា "ការវាយតម្លៃផលប៉ះពាល់របស់ប្រទេសចិនទៅលើភាពក្រីក្រនៅមហាអនុតំបន់មេគង្គ" ទើបបានបោះពុម្ពផ្សាយនាពេលថ្មីៗ ដោយវិទ្យាស្ថានសិក្សាពីតំបន់អាស៊ីអាគ្នេយ៍ (ISEAS) នៅប្រទេសសិង្ហបុរី។

### កម្មវិធីធនធានធម្មជាតិ និង បរិស្ថាន (NRE)

ក្រុមស្រាវជ្រាវទើបបញ្ចប់រួចរាល់នូវគម្រោងស្ដីពី "វិធីសាស្ត្រជាក់ស្ដែង សម្រាប់ជួយទ្រទ្រង់ភាពប្រកួតប្រជែងនៃប្រទេសមានចំណូលទាប/មធ្យមកម្រិតទាប នៅក្នុងពិភពលោកដែលកំពុងមានកំហិតផ្នែកកាបូន"។ របាយការណ៍ស្ដីពី "យេនឌ័រ និងអភិបាលកិច្ចទឹក" ក្រុមស្រាវជ្រាវកំពុងត្រួតពិនិត្យឡើងវិញមុនយកទៅបោះពុម្ពផ្សាយជាឯកសារពិភាក្សា ហើយឯកសារពិភាក្សាស្ដីពី "សមត្ថភាពបន្សាំរបស់ប្រជាជនជនបទ ក្នុងតំបន់កសិអេកូឡូស៊ីចម្រុះៗ កំពុងចងក្រងឡើង។ ការសិក្សាទាំងពីរនេះទទួលបានជំនួយទ្រទ្រង់ពី ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្ដរជាតិ ស៊ុយអែត (Sida)។

ការចុះសិក្សាដល់កន្លែងជាដំបូងសម្រាប់គម្រោង "ប្រទេសចិនឈានឡើងកម្រិតសកល" ដែលទទួលមូលនិធិពី ក្រុមប្រឹក្សាស្រាវជ្រាវសេដ្ឋកិច្ចនិងសង្គម (ESRC) កំពុងដំណើរការទៅមុខ។ សម្រាប់គម្រោងទទួលមូលនិធិពី IDRC ស្ដីពី "ការប្រែប្រួលអាកាសធាតុ និងអភិបាលកិច្ចទឹកនៅកម្ពុជា" របាយការណ៍ដំបូងបានទទួលការយល់ព្រម និងកំពុងចងក្រងជាឯកសារពិភាក្សា។ ក្រុមស្រាវជ្រាវគម្រោងនេះ ក៏បានរៀបចំសិក្ខាសាលាកម្រិតសហគមន៍ចំនួនបី និងចាប់ផ្ដើមដំណើរការជ្រើសរើសបេក្ខជន ៥នាក់ សម្រាប់អាហារូបករណ៍ថ្នាក់អនុបណ្ឌិត និង ១២ នាក់សម្រាប់អាហារូបករណ៍ថ្នាក់បរិញ្ញាប័ត្រនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម (RUA) និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC)។ ក្រុមស្រាវជ្រាវនៃកម្មវិធី NRE ក៏កំពុងអនុវត្តគម្រោងថ្មីមួយ ស្ដីពី "ការកាត់បន្ថយភាពងាយរងគ្រោះពីទឹកជំនន់ និងការរាំងស្ងួត និងការបង្កើនផលិតភាពកសិកម្ម" ដោយទទួលបានមូលនិធិពី DanChurchAid ។

ក្រុមស្រាវជ្រាវកម្មវិធី NRE បានដាក់សំណើស្រាវជ្រាវរួមគ្នាពីរ គឺទី១ ដាក់ជូន ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នូវសំណើអំពី "ការបញ្ជ្រាបនូវភាពធន់នឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងការធ្វើផែនការអភិវឌ្ឍ" ដែលគ្រោងអនុវត្តជាមួយទីប្រឹក្សា Hatfield (Hatfield Consultants) និងទី២ ដាក់ជូន កម្មវិធីអាកាសធាតុ និងចីរភាពទឹក នៃមូលនិធិវិទ្យាសាស្ត្រជាតិ នូវសំណើអំពី "ការប្រែប្រួលអាកាសធាតុ និងការរក្សានិរន្តរភាពទឹក៖ ទំនាក់ទំនងផ្នែកធារាសាស្ត្រ, សេវាអេកូឡូស៊ី និងភាពបន្សាំផ្នែកសេដ្ឋកិច្ចសង្គមកិច្ច នៅក្នុងប្រព័ន្ធវាលទំនាបតាមដងទន្លេមេគង្គក្រោមនៃប្រទេសកម្ពុជា" ដែលគ្រោងអនុវត្តជាមួយ សាកលវិទ្យាល័យជីកាហ្គោ។

### កម្មវិធីភាពក្រីក្រ កសិកម្ម និងអភិវឌ្ឍន៍ជនបទ (PARD)

ក្រុមស្រាវជ្រាវគម្រោង "ការសិក្សាវាយតម្លៃគោល លើកម្មវិធីការជួយដោះស្រាយបញ្ហាភាពងាយរងគ្រោះនៅតាមជនបទ និងស្ថិរភាពនៃប្រព័ន្ធអេកូឡូស៊ី (HARVEST)" បានបញ្ជូនរបាយការណ៍សម្រេច និងធ្វើបទបង្ហាញពីលទ្ធផលរកឃើញ ជូនក្រុម USAID កាលពីចុងខែសីហា ហើយគម្រោងក៏បានចប់រួចរាល់។

នាបច្ចុប្បន្ន ក្រុមស្រាវជ្រាវកំពុងអនុវត្តគម្រោងសិក្សា ចំនួនបួន។ ដំណាក់កាលទី១ នៃការសិក្សាពី "ការកសាងគោលនយោបាយកសិកម្មសម្រាប់ប្រព័ន្ធកសិកម្មផ្អែកលើដំណាំស្រូវនៅកម្ពុជា និងឡាវ" បានចប់សព្វគ្រប់។ ករណីសិក្សាចំនួនបួនស្ដីពីឥណទានកសិកម្ម ខ្សែចង្វាក់តម្លៃដី ខ្សែចង្វាក់តម្លៃអង្ករ និងការដាំស្រូវតាមកិច្ចសន្យា បានអនុវត្តរួចរាល់សម្រាប់ការបោះពុម្ពផ្សាយនៅក្នុងសៀវភៅរបស់ មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្ដរជាតិ (ACIAR) មានចំណងជើងថា "គោលនយោបាយ និងការអនុវត្តជាក់ស្ដែង៖ ការប្រើភស្តុតាងបានពីការសិក្សាដល់កន្លែង ដើម្បីផ្ដល់ព័ត៌មានដល់ការកំណត់គោលនយោបាយស្រូវនៅតំបន់មេគង្គ"។ ជំហានទី២ នៃគម្រោងនេះ កំពុងដំណើរការដោយមានការអនុវត្តករណីសិក្សាចំនួនពីរ គឺ "ទីផ្សារ និងផលិតកម្មសត្វចិញ្ចឹម" និង "ឥទ្ធិពលនៃការផ្សព្វផ្សាយបច្ចេកទេសកសិកម្មទៅលើផលិតកម្មស្រូវ"។ លទ្ធផលដំបូងៗ មានយកទៅធ្វើជាបទបង្ហាញក្នុងសិក្ខាសាលាថ្នាក់តំបន់មួយ នៅរាជធានីភ្នំពេញ នៅដើមខែវិច្ឆិកា។ ការចុះប្រមូលទិន្នន័យដល់កន្លែង សម្រាប់ការសិក្សាផ្ដល់មូលនិធិដោយ Sida ស្ដីពី "ផលប៉ះពាល់នៃការធ្វើកសិកម្មតាមកិច្ចសន្យាទៅលើជីវភាពរស់នៅរបស់ម្ចាស់ដីតូចៗ" ជិតចប់រួចរាល់។ សម្រាប់គម្រោងផ្ដល់មូលនិធិដោយ Sida ស្ដីពី "ការសិក្សាពីយន្តកម្មនៅតាមកសិដ្ឋាន និងនិន្នាការទីផ្សារពលកម្មក្នុងវិស័យកសិកម្ម" នោះក្របខ័ណ្ឌស្រាវជ្រាវបានកំណត់រួចជាស្រេច រីឯទិន្នន័យប្រភពទី២ ក៏បានប្រមូលរួចរាល់ ហើយការវិភាគទិន្នន័យកំពុងដំណើរការទៅមុខ។ របាយការណ៍ព្រាងដំបូងសម្រាប់គម្រោង "ស្ថានភាពនៃការអភិវឌ្ឍឧស្សាហកម្មជីនៅកម្ពុជា" ដែលជាការសិក្សាឆ្លងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងអាស៊ីកណ្ដាល និងផ្ដល់មូលនិធិដោយ USAID តាមរយៈ វិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្ដរជាតិ (IFPRI) បានចប់សព្វគ្រប់ ហើយលទ្ធផលរកឃើញជាដំបូងៗ បានយកទៅធ្វើបទបង្ហាញក្នុងសិក្ខាសាលាអន្ដរជាតិ កាលពីថ្ងៃទី ២៥-២៧ កញ្ញា ២០១៣ នៅខេត្តសៀមរាប។

ក្រុមស្រាវជ្រាវកម្មវិធី PARD ក៏កំពុងចូលរួមក្នុងគម្រោងស្រាវជ្រាវរួមគ្នាចំនួនបីដែរ គឺ៖ គម្រោង "ការកសាងប្រព័ន្ធសុខាភិបាលអំណោយផលដល់ជនក្រីក្រ ក្នុងពេលកសាងប្រទេសឡើងវិញបន្ទាប់ពីបានបញ្ចប់ទំនាស់ (ReBUILD)" ដែលត្រូវអនុវត្តជាមួយ

កម្មវិធី SD, គម្រោង "ចំណាកស្រុកកម្លាំងពលកម្មនៅកម្ពុជា៖ មូលហេតុ និងផលប៉ះពាល់លើភាពក្រីក្រ វិសមភាព និងផលិតភាព" ត្រូវអនុវត្តជាមួយកម្មវិធី ETRC និង គម្រោង "ការពិនិត្យពីការយល់ឃើញ និងការរីកលូតលាស់ផ្នែកវិជ្ជាជីវៈរបស់ស្ត្រី នៅវិទ្យាស្ថាន CDRI" ដែលជាគំនិតផ្តួចផ្តើមរបស់ក្រុមការងារយេនឌ័ររបស់ CDRI។

## កម្មវិធីអភិវឌ្ឍន៍សង្គម (SD)

ក្រុមស្រាវជ្រាវកម្មវិធីនេះបានបង្ហើយគម្រោងបីគឺ៖ គម្រោង "ការពិនិត្យផ្ទៀងផ្ទាត់លទ្ធផលផ្នែកអនាម័យនៅកម្ពុជា" "ការដាំស្រូវតាមកិច្ចសន្យា" និង "ប្រព័ន្ធពិនិត្យតាមដានការប្រែប្រួលទាក់ទងនឹងការអភិវឌ្ឍ" ដែលជាគម្រោងរួមគ្នាជាមួយកម្មវិធី DGPSR និង ETRC ដោយក្នុងនោះ SD បានចូលរួមចងក្រង ២ ជំពូក ក្នុងចំណោម ៥ជំពូក។ ក្រុមស្រាវជ្រាវកម្មវិធី SD ក៏បានចងក្រងអត្ថបទមួយ ស្តីពី "ការជំរុញឲ្យការដាំស្រូវតាមកិច្ចសន្យាមានដំណើរការល្អសម្រាប់កសិករតូចតាច និងកសិពាណិជ្ជកម្ម" សម្រាប់បោះពុម្ពផ្សាយនៅក្នុងទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា។

គម្រោងសិក្សាធំៗបីកំពុងដំណើរការទៅមុខ។ គម្រោង "ReBUILD" កំពុងដំណើរការតាមការគ្រោងទុក។ គម្រោងនេះទទួលជំនួយទ្រទ្រង់ពី ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (អង់គ្លេស) (DFID) និងចែកជា ៣ អនុគម្រោងស្តីពី ហិរញ្ញប្បទានផ្នែកសុខភាព, ធនធានមនុស្សផ្នែកសុខាភិបាល និងការចុះកិច្ចសន្យាផ្នែកសុខាភិបាល។ ការសម្ភាសដល់កន្លែងបានអនុវត្តរួចប្រហែលពីរភាគបី ដោយការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះមួយចំនួន ត្រូវពន្យាពេល ព្រោះមានការបោះឆ្នោតថ្នាក់ជាតិ។ សមាជិកក្រុមស្រាវជ្រាវ ៥រូប បានទៅចូលរួមក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៅក្រុង Liverpool ប្រទេសអង់គ្លេស កាលពីថ្ងៃទី ៤-១៦ ខែកញ្ញា។ អនុគម្រោងពីរ ក្នុងចំណោមអនុគម្រោងបួននៃ "ការសិក្សាពីពលកម្មកុមារ" កំពុងអនុវត្តទៅមុខ គឺអនុគម្រោងទី១ ស្តីពីការងារកុមារបម្រើតាមផ្ទះ និង ទី២ ស្តីពីផលប៉ះពាល់នៃចំណាកស្រុករបស់មនុស្សពេញវ័យ ទៅលើពលកម្មកុមារ។ គម្រោងសិក្សានេះ ជាផ្នែកមួយនៃគម្រោង Cambodian-EXCEL របស់អង្គការ World Vision Cambodia និងទទួលមូលនិធិពី United States Department of Labor (USDOL) សម្រាប់រយៈពេលបួនឆ្នាំ ចាប់ពីដើមឆ្នាំ២០១៣ ដល់ចុងឆ្នាំ២០១៦។ ការចុះសិក្សាដល់កន្លែងសម្រាប់អនុគម្រោងទី១ (មានអ្នកឆ្លើយសម្ភាសន៍ ១០០០នាក់ និងអ្នកផ្តល់ព័ត៌មានគន្លឹះ ៣០នាក់) បានអនុវត្តជិតចប់រួចរាល់ ប៉ុន្តែការចុះសិក្សាដល់កន្លែងសម្រាប់អនុគម្រោងទី២ ត្រូវពន្យាពេល ដោយសារត្រូវកែសម្រួលកម្រងសំណួរឲ្យបានស្រេចបាច់សិន។ ការចុះសិក្សាដល់កន្លែងសម្រាប់អនុគម្រោងទាំងពីរនេះ រំពឹងថា ចប់សព្វគ្រប់អស់ក្នុងខែតុលា។ គម្រោងកំពុងអនុវត្តមួយទៀតគឺ "ការវាយតម្លៃលើយុទ្ធនាការផ្សព្វផ្សាយពី ការផ្តល់អាហារបន្ថែម សម្រាប់កុមារអាយុពី ៦ ទៅ ២៤ខែ នៅកម្ពុជា" ដែលជាការសិក្សាបែបគុណភាពអំពី កម្មវិធីផ្តល់អាហារូបត្ថម្ភដល់កុមារនៅក្នុងប្រទេស និងទទួលបានមូលនិធិពី UNICEF។ ក្នុងនេះការសិក្សាដល់កន្លែងបានអនុវត្តចប់សព្វគ្រប់ ហើយសម្លេងថតទុកក្នុងពេលធ្វើសម្ភាសន៍កំពុងយកមកចម្លងចេញជាលាយលក្ខណ៍អក្សរ។ គម្រោងសិក្សានេះរំពឹងថាចប់សព្វគ្រប់អស់ក្នុងខែវិច្ឆិកា។

## Cambodia Development Review—2013 Subscription Rates

**Domestic Subscription (Individual)**

❒ English edition ($14) ❒ Khmer edition (5,000 riels) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed........................................

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❒ English edition ($60 for five copies) ❒ Khmer edition (20,000 riels for five copies) Payment by ❒ cash or ❒ local cheque (please add $2 to cover bank charges). Total payment enclosed........................................

**International Subscription (Individual)**

| | | |
|---|---|---|
| ❒ Thailand, Laos, Vietnam | ❒ English edition ($25)* | ❒ Khmer edition ($15)* |
| ❒ Asia and Europe | ❒ English edition ($30)* | ❒ Khmer edition ($20)* |
| ❒ Americas and Africa | ❒ English edition ($35)* | ❒ Khmer edition ($25)* |

**Details for payment by telegraphic transfer**

| | |
|---|---|
| Account Name: | CDRI |
| Account Number: | 133451 |
| Bank Name: | ANZ Royal Bank (Cambodia) Ltd |
| Bank Address: | Phnom Penh, Cambodia Head Office |
| Swift Code: | ANZBKHPP |
| Receiver Correspondent Bank: | JP Morgan Chase Manhattan Bank, N.A., New York, USA<br>Swift Code: CHASUS33 |

Title: ❒Mr ❒Ms ❒Dr ❒Other ........................................

First name: .................... Last name: .................... Position: ....................

Organisation / Company: ........................................

Address (CCC Box if applicable): ........................................

City / Province: .................... Country: ....................

Telephone: .................... Fax: ....................

e-mail: .................... ❒ Tick to receive regular information about CDRI publications via e-mail

To subscribe, please fill in this form and return it to CDRI with your payment. Do not send cash through the post.
You will need to inform the Publishing Department at CDRI if your contact details change.

*តពីទំព័រ ២៤* **ការគោរពលើកសរសើរដល់...**

លោកស្រីយកចិត្តទុកដាក់ជាខ្លាំងលើការយល់ដឹង និងបញ្ច្រាបបញ្ហាយេនឌ័រ បានតស៊ូមតិយ៉ាងស្វិតស្វាញ ការពារសិទ្ធិ និងផលប្រយោជន៍របស់ស្ត្រី និងក្មេងស្រី ប៉ុន្តែតែងគូសបញ្ជាក់ជានិច្ចថា សមធម៌យេនឌ័រវាជាប់ពាក់ព័ន្ធទាំងស្ត្រី និងបុរស វាជាទំនួលខុសត្រូវរួមគ្នាដោយបុរសនិងស្ត្រីត្រូវធ្វើការជាមួយគ្នាដើម្បីសម្រេចបាន សមធម៌យេនឌ័រ និងសមធម៌ក្នុងសង្គម។ លោកស្រីជាកម្លាំងចម្បងជំរុញការកសាងគោលការណ៍ណែនាំផ្នែកយេនឌ័ររបស់ CDRI ដើម្បីបំផុសការយកចិត្តទុកដាក់ និងបញ្ច្រាបបញ្ហាយេនឌ័រនៅក្នុងការស្រាវជ្រាវ និងក្នុងរបៀបរបបនៃស្ថាប័នយើងខ្ញុំ ដោយបង្កើតបានជាក្រុមការងារយេនឌ័រមួយដែលមានសមាជិកជាស្ត្រី និងបុរសមកពីគ្រប់ផ្នែកក្នុងវិទ្យាស្ថាន ដើម្បីធ្វើការរួមគ្នាញ៉ាំងឲ្យបញ្ហាយេនឌ័រក្លាយជាការងារប្រចាំថ្ងៃរបស់យើងខ្ញុំគឺ មិនមែនគ្រាន់តែជាការសន្យាអះអាងលើក្រដាសនោះទេ។

ក្នុងតួនាទីជាទីប្រឹក្សាស្រាវជ្រាវ លោកស្រីជាអ្នកជួយណែនាំ និងជាអ្នកគាំទ្រមិនចេះនឿយហត់ដល់អ្នកស្រាវជ្រាវកម្ពុជាក្មេងៗ ជាពិសេសអ្នកស្រាវជ្រាវជាស្ត្រី ព្រមទាំងឧស្សាហ៍ព្យាយាមជានិច្ចជួយកែលំអគុណភាពរបៀបរៀបចំការស្រាវជ្រាវ វិធីសាស្ត្រស្រាវជ្រាវ និងជំនាញសរសេររបស់ពួកគេ។ ជារៀងរាល់ថ្ងៃនៅក្នុង CDRI លោកស្រីតែងជួបពិភាក្សាយ៉ាងអំណត់ជាមួយអ្នកស្រាវជ្រាវ ដើម្បីជួយមតិ និងផ្តល់ការណែនាំ ទាំងផ្ទាល់មាត់ និងជាសារ/ចំណារផ្សេងៗ ដើម្បីកសាងគោលគំនិតស្រាវជ្រាវឲ្យបានកាន់តែប្រសើរ ពង្រឹងការវិភាគ ព្រមទាំងកែលំអការផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវ និងបង្កើនផលពាក់ព័ន្ធផ្នែកគោលនយោបាយ។ លោកស្រីយកចិត្តទុកដាក់លើរូបគេ និងគុណភាពការងាររបស់ពួកគេ ហើយពួកគេក៏យកចិត្តទុកដាក់ និងវាយតម្លៃខ្ពស់ ដល់ការតាំងចិត្តជួយជ្រោមជ្រែងដល់ពួកគេនេះដែរ។

ស្នាដៃដ៏ចម្បងមួយនាពេលថ្មីៗរបស់លោកស្រី Pem ដោយរួមសហការជាមួយច្រើននាក់ទៀតដែលនៅទីនេះដែរ គឺការដឹកនាំ និងរៀបចំកម្មវិធីបណ្តុះបណ្តាលដ៏សំខាន់បំផុតមួយស្តីពី ការរចនារៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវ។ ដោយបានគិតគូរជាពិសេសសម្រាប់បរិបទកម្ពុជា កម្មវិធីនេះបានផ្តល់អត្ថប្រយោជន៍ច្រើនណាស់ដល់អ្នកស្រាវជ្រាវក្មេងៗមកពី CDRI និងពីស្ថាប័នជាសមាជិក DRF ឯទៀតៗ ហើយលទ្ធផលចម្បង គឺការកសាងសៀវភៅណែនាំដ៏សំខាន់បំផុតមួយសម្រាប់ជួយដល់កិច្ចប្រឹងប្រែងស្រាវជ្រាវ និងបណ្តុះបណ្តាលរបស់អ្នកស្រាវជ្រាវកម្ពុជា។

ជាចំណុចចុងក្រោយ យើងនៅចាំជានិច្ចថា ក្រៅពីមានសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងគោលដៅដ៏សំខាន់នោះ លោកស្រី Pem ថែមទាំងប៉ិនប្រសប់និយាយកំប្លែងស្លូត មានស្មារតីរហ័សរហួន ធ្វើឲ្យអ្នកនៅជុំវិញមានអារម្មណ៍ធូរស្រាលល្អណាស់។ ក្នុងពេលដំណើរការវេទិកាពីរថ្ងៃខាងមុខនេះ និងតទៅមុខទៀត យើងគួរនឹកគិតដល់ និងអបអរសាទរចំពោះមត៌ក និងដំណើរជីវិតរបស់ស្ត្រីដ៏វិសេសមួយរូបនេះ។

ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់*
*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១៧ លេខ៣ ខែកញ្ញា ឆ្នាំ២០១៣

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដង ក្នុងមួយឆ្នាំជាភាសាខ្មែរ និងភាសាអង់គ្លេសនៅពេលដំណាលគ្នា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហាអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា។ អត្ថបទតាមដានសេដ្ឋកិច្ច ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរការនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន។ លិខិត ត្រូវចុះហត្ថលេខា អាចផ្ទៀងផ្ទាត់បាន មានលេខទូរស័ព្ទ និងអាសយដ្ឋាន។ អ្នកនិពន្ធ ត្រូវទាក់ទងវិទ្យាស្ថាន CDRI មុននឹងផ្តល់អត្ថបទ ទោះជាឯកសារនោះមិនទាន់រៀបរយក៏ដោយ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសម្រាប់ការបោះពុម្ព។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
☛ អាសយដ្ឋាន ៥៦ ផ្លូវ ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា
⊠ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥ ២៣) ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣ 🖷 (៨៥៥ ២៣) ៨៨០ ៧៣៤
e-mail: cdri@cdri.org.kh
website: www.cdri.org.kh

9 789995 052065

គ្រឹះស្ថានផ្សាយៈ វបសអ
គ្រប់គ្រងកែសំរួលៈ យូ សិទ្ធិរិទ្ធ
កែសំរួលផលិតកម្មៈ អ៊ុំ ចាន់ថា និង ម៉េន ច័ន្ទធីតា
ជំនួយការកែសំរួលៈ ខេង សេង
សហគ្រាសបោះពុម្ព សាលាបច្ចេកទេសដុនបូស្កូ ភ្នំពេញ រូបភាពទំព័រមុខៈ រូបភាព វបសអ

© រក្សាសិទ្ធិ ២០១៣ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងមធ្យោបាយផ្សេងៗដូចជាៈ អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វិទ្យាស្ថានCDRI ឡើយ។

ISSN 1560-7615 / ISBN 978-99950-52-06-5

គំនិត ការលើកពីហេតុការណ៍ និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង *ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់អ្នកនិពន្ធ។ ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វិទ្យាស្ថាន CDRI ទេ។

រាល់ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI មានផ្តល់ជូនដោយឥតគិតថ្លៃតាមរយៈគេហទំព័រ www.cdri.org.kh

## ការគោរពលើកសរសើរដល់ បណ្ឌិត Rebecca (Pem) Catalla ដោយ លោក Larry Strange នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI ក្នុងពិធីបើកវេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣



ឯកឧត្តម លោកជំទាវ សហសេវិក និងប្រិយមិត្តទាំងអស់

វេទិកាសិក្សាស្រាវជ្រាវអភិវឌ្ឍន៍នាឆ្នាំនេះ យើងអាចនិយាយបានថា វាផ្អែមផង និងល្វីងផង សម្រាប់វិទ្យាស្ថានCDRIក៏ដូចជាសហសេវិកជាអ្នកស្រាវជ្រាវទាំងឡាយនៅទីនេះ។ វាផ្អែមព្រោះយើងមកជួបជុំគ្នាដោយរីករាយម្តងទៀតក្នុងពីរថ្ងៃខាងមុខនេះ។វាល្វីងព្រោះកាលពីយប់ថ្ងៃសុក្រកន្លងទៅ វិទ្យាស្ថាន CDRI និងសហគមន៍អ្នកស្រាវជ្រាវកម្ពុជាទាំងមូល បានបាត់បង់សមាជិកដ៏ថ្លៃថ្លា និងមានប្រជាប្រិយភាពបំផុតមួយ គឺបណ្ឌិត Rebecca ( Pem ) Catalla ដែលបានទទួលមរណភាពភ្លាមៗ ដោយសារការគាំងបេះដូង។ ខ្ញុំសូមឆ្លៀតយកឱកាសនាពេលព្រឹកនេះ ដើម្បីចូលរួមជាមួយសហសេវិក និងមិត្តភក្តិជាច្រើនទៀត សំដែងនូវការគោរព និងលើកសរសើរដល់ស្ត្រីដ៏វិសេសនេះ និងអបអរសាទរចំពោះមត៌កដ៏ប្រសើរដែលលោកស្រីបានបន្សល់ទុក។

ក្នុងរយៈពេលជាង១៥ឆ្នាំដែលលោកស្រីបានមកបម្រើការនៅកម្ពុជា លោកស្រីបានបូជាពេលវេលាទាំងមូល ទៅលើការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍។ លោកស្រីជាអ្នកស្រាវជ្រាវដ៏ចំណានផ្នែកគោលនយោបាយសង្គម ដោយធ្លាប់ធ្វើការជាមួយមន្ទីរក្រសួងរដ្ឋ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលទាំងក្នុងស្រុក និងអន្តរជាតិ និងស្ថាប័នស្រាវជ្រាវនិងកសាងសមត្ថភាពនានា លើបញ្ហាអភិវឌ្ឍន៍ច្រើនបែបយ៉ាង ដូចជា ភាពក្រីក្រ, ជីវភាពរស់នៅ, សុខភាព និងសុខមាលភាពមាតា, លទ្ធភាពទទួលបានការអប់រំ និងសេវាថែទាំសុខភាព, សុខមាលភាព និងអាហារូបត្ថម្ភរបស់កុមារ, តម្លៃផ្នែកសេដ្ឋកិច្ចសង្គមកិច្ចរបស់ស្ត្រីក្នុងការអភិវឌ្ឍ, ការកសាងសន្តិភាព និងដោះស្រាយទំនាស់, ការយល់ដឹង និងបញ្ជ្រាបបញ្ហាយេនឌ័រ, ប្រជាជនមានផ្ទុកមេរោគអេដស៍, និងការអប់រំ និងផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងក្មេងស្រី។

លោកស្រី Rebecca ( Pem ) Catalla មានសីលធម៌ផ្ទាល់ខ្លួន និងឧត្តមគតិវិជ្ជាជីវៈរឹងមាំណាស់ និងមានការប្តេជ្ញាចិត្តខ្ពស់លើកកម្ពស់យុត្តិធម៌ក្នុងសង្គម សមត្ថភាពវិជ្ជាជីវៈ ភាពសុចរិតស្អាតស្អំ ផលិតភាព និងគណនេយ្យភាពស្ថាប័ន។ លោកស្រីតែងជាសមាជិកល្អក្នុងក្រុម ជាស្ពានដ៏សំខាន់តភ្ជាប់សមាជិកថ្នាក់ក្រោម ទៅនិងសមាជិកថ្នាក់លើនៅក្នុងអង្គការយើងខ្ញុំ ដោយជានិច្ចកាលជួយធានាឲ្យគេបានដឹងឮពីមតិយោបល់ និងដោះស្រាយ រាល់តម្រូវការរបស់អ្នកស្រាវជ្រាវក្មេងៗ។

*តទៅទំព័រ ២៣*